ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីនៅក្នុង ឃុំអង្កោល

## ឆ្នាំ ២០១០-២០២២

## ស្រុក ដំណាក់ចង្អើរ ខេត្ត កែប



**រៀបចំដោយ:** គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

**គាំទ្រដោយ:** ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក

**ខែ ធ្នូ ឆ្នាំ ២០០៩**

# មាតិកា


**អារម្ភកថា** ........ ១

**សេចក្តីផ្តើម** ........ ២

**ជំពូក១: ព័ត៌មាន និង ទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ** ........ ៤

**១.១ ស្ថានភាពទូទៅ** ........ ៤

១.១.១ ទីតាំងរដ្ឋបាល ........ ៤

១.១.២ ប្រជាសាស្ត្រ ........ ៤

១.១.៣ ភាពគ្មានដីធ្លី ........ ៥

១.១.៤ ស្ថានភាពសេដ្ឋកិច្ច ........ ៥

១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ ........ ៦

១.១.៦ ស្ថានភាពសុខាភិបាល ........ ៧

១.១.៦.១ ផ្នែកសុខាភិបាល ........ ៧

១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត ........ ៩

**១.២ ស្ថានភាពភូមិសាស្ត្រ** ........ ១០

១.២.១ ទីតាំងភូមិសាស្ត្រ ........ ១០

១.២.២ អាកាសធាតុ ........ ១០

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ........ ១១

**១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ........ ១១

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី ........ ១៦

១.៣.២ ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី ........ ១៦

១.៣.៣ ផលិតកម្មកសិកម្ម ........ ១៧

១.៣.៣.១ ធនធានព្រៃឈើ ........ ១៧

១.៣.៣.២ ធនធានជលផល ........ ១៨

**១.៤ ទីផ្សារ និង ខ្សែសង្វាក់ផលិតផល** ........ ១៩

១.៤.១ ទីផ្សារ និង តម្លៃកសិផល ផល និង អនុផលព្រៃឈើ និងផលនេសាទ ........ ១៩

១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល ........ ១៩

១.៤.៣ ឱកាស ឧបសគ្គ ........ ១៩

**ជំពូក២: ការវិភាគពី ឧបសគ្គ តម្រូវការសំរាប់អនាគត និង សក្តានុពល** ........ ២១

**២.១ តំបន់រសើប** ........ ២៣

**២.២ ការប្រឈម/ឧបស័គ្គ** ........ ២៥

**២.៣ កំណត់តម្រូវការនៃការអភិវឌ្ឍ និងគោលដៅយុទ្ធសាស្រ្តឃុំ** ........ ២៥

**២.៤ តម្រូវការសំរាប់អនាគត** ........ ២៦

២.៤.១ ប្រជាសាស្រ្ត ........ ២៦

២.៤.១.១ អត្រាកំណើន ........ ២៦

២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ ........ ២៧

២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន ........ ២៨

២.៤.៣ តម្រូវការដីកសិកម្ម ........ ២៨

២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ........ ៣០

២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធសង្គម ........ ៣១

២.៤.៥.១ តម្រូវការសាលារៀន ........ ៣១

២.៤.៥.២ សេវាកម្មសុខភាព និងផ្គត់ផ្គង់ទឹកស្អាត ........ ៣២

២.៤.៥.៣ ផ្នែកវប្បធម៌ ........ ៣៣

២.៤.៥ .៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និង ប្រពន្ធ័ស្រោចស្រព ........ ៣៣

**ជំពូក៣: ផែនការប្រើប្រាស់ដីអនាគត** ........ ៣៤

**៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី** ........ ៣៤

៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល ........ ៣៤

៣.១.២ តម្រូវការដីតាមប្រភេទ ........ ៣៥

**៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់** ........ ៣៧

៣.២.១ បទបញ្ញត្តិលើការប្រើប្រាស់ដី និង អនុសាសន៍ ........ ៣៧

៣.២.២ ផែនទីប្រើប្រាស់ដីអនាគត ........ ៣៩

៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី ........ ៣៩

# អារម្ភកថា

ផែនការប្រើប្រាស់ដីនៅក្នុង ឃុំអង្គោល ស្រុក ដំណាក់ចង្អើរ ខេត្តកែប រយៈពេល១៥ឆ្នាំ ត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាឃុំអង្គោល និង មានការចូលរួមពីគណៈកម្មការកសាងផែនការនិងថវិកា និងប្រជាពលរដ្ឋ គ្រប់ស្រទាប់សហការពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី ថ្នាក់ស្រុក (D-LUP) ពីក្រុម អ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី ថ្នាក់ខេត្ត (P-LUP) និងគាំទ្របច្ចេកទេសពីក្រុមការងារសមាស ភាគរៀបចំដែនដី (Land Management Component) របស់អគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រោមការជួយឧបត្ថម្ភថវិកាពី អង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅ ក្នុងប្រទេសកម្ពុជា ។

គោលបំណងចំបងនៃផែនការប្រើប្រាស់ដី នៅក្នុងឃុំអង្គោលនេះ ជាត្រីវិស័យតំរង់ទិសដល់ការអភិវឌ្ឍន៍ និង ដើម្បីគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍របស់ឃុំទាំងមូលឱ្យចំទិសដៅពីតំរូវការបញ្ហារបស់ប្រជា ពលរដ្ឋស្របតាមគោលនយោបាយ កាត់បន្ថយភាពក្រីក្រ និងគោលនយោបាយ វិមជ្ឈការ និង វិសហមជ្ឈការ សំដៅពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល ដើម្បីលើកស្ទួយសេដ្ឋកិច្ច និង ជីវភាពរស់នៅរបស់ប្រជា ពលរដ្ឋឱ្យកាន់តែប្រសើរឡើង ។

ក្នុងនាមក្រុមប្រឹក្សា ឃុំអង្គោល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ គណៈកម្មការកសាងផែនការ ជនបង្គោល ប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធមួយចំនួន ដែលបានចូលរួមយ៉ាងសស្រាក់សស្រាំ បានលើកឡើងពីបញ្ហា មូលហេតុជាក់ស្តែងនានាដែលបានជួបប្រទះកន្លងមក និង តំរូវការអភិវឌ្ឍន៍ជាពិសេសចំពោះក្រសួងរៀបចំ ដែនដីនគរូបនីយកម្ម និង សំណង់ និងអង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូតដាណឺម៉ាក ប្រចាំនៅក្នុងប្រទេសកម្ពុជាដែលបានផ្តល់ថវិកាជំនួយ សំរាប់ដំណើរការរៀបចំផែនការនេះ សូមថ្លែង អំណរគុណផងដែរដល់ក្រុមការងាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកែប ដែលបានជួយសម្របសម្រួល ក្នុងការ រៀបចំ ផែនការនេះឱ្យសម្រេចបានជោគជ័យ និងសូមថ្លែងអំណរគុណ ចំពោះការចូលរួមរបស់មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ជាពិសេសអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត រដ្ឋបាលព្រៃឈើ មន្ទីរកសិកម្មខេត្ត មន្ទីរបរិស្ថានខេត្ត ។

ក្រុមប្រឹក្សាឃុំអង្គោល ក៏មិនអាចបំភ្លេចបានផងដែរ នូវការជួយឧបត្ថម្ភ គាំទ្រ បង្ហាត់បង្ហាញទាំងទ្រឹស្តី និងបច្ចេកទេស អនុវត្តផ្ទាល់លើការងាររៀបចំផែនការប្រើប្រាស់ដីធ្លី ពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការ ប្រើប្រាស់ដីថ្នាក់ខេត្ត (P-LUP) ថ្នាក់ស្រុក (D-LUP) និងក្រុមការងារថ្នាក់ជាតិ របស់សមាសភាគ រៀបចំដែនដី ។

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថាសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ នឹងបានយល់ដឹងអំពីស្ថានភាព និងតម្រូវការ ព្រមទាំងបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធ នឹងការប្រើប្រាស់ដី ដែលរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ ឃុំ អង្គោល ហើយផែនការប្រើប្រាស់ដីធ្លីនេះ នឹងចូលរួមចំណែកអភិវឌ្ឍន៍ មូលដ្ឋានតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាល ប្រកបដោយជោគជ័យ ។

ធ្វើនៅ អង្គោល ថ្ងៃទី............ខែ...............ឆ្នាំ ២០០៩

**មេឃុំ អង្គោល**

## សេចក្តីផ្តើម

ឃុំអង្កោលមានទីតាំងសាសាឃុំស្ថិតនៅក្នុងភូមិអំពែង ហើយ មានចំងាយប្រហែល ៤គីឡូម៉ែត្រ ពីសាសាស្រុក ដំណាក់ចង្អើរ ។ ឃុំអង្កោលមានចំនួន ៤ ភូមិគឺៈ

១- ភូមិអំពែង

២- ភូមិទួលសាងាំ

៣- ភូមិកោះសោម

៤- ភូមិអង្កោល

ឃុំនេះមានផ្ទៃដី ៣២៦៨ ហិចតា មានទីតាំងសាសាឃុំស្ថិតនៅក្នុង ភូមិអំពែង មានចំងាយប្រហែល ៤គីឡូម៉ែត្រ ពីសាសាស្រុក ដំណាក់ចង្អើរ ។ មានព្រំប្រទល់ៈ

- ខាងជើងទល់និង ឃុំ ពងទឹក
- ខាងត្បូងទល់និង ឆ្នេរអង្កោល
- ខាងកើតទល់ ឃុំ ស្វាយទង ស្រុកកំពង់ត្រាច
- ខាងលិចទល់និង ឃុំ ពងទឹក

ដោយឃុំនេះមានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍន៍ លើវិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ហើយទោះបីជាឃុំនេះមានចំងាយប្រមាណ ២០,៥ គីឡូម៉ែត្រ ឆ្ងាយពី សាលាខត្តកែប ក៏ដោយ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់កសាងបាន នូវសមិទ្ធិផលជាច្រើនដូចជា : ផ្លូវក្រាលគ្រួសក្រហម, ផ្លូវលំដី, ស្ពាន,លូ,ប្រឡាយ សាលារៀន មន្ទីរពេទ្យ ។ល។ នៅឆ្នាំ២០០៩ដោយមានការគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដី(Land Management Component) របស់អគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមការជួយឧបត្ថម្ភថវិកាពីអង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូត ដាណឺម៉ាកប្រចាំនៅក្នុងប្រទេសកម្ពុជា ហេតុដូច្នេះហើយទើបក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការ កសាងផែនការ និងថវិកា បានរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំអោយស្របតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល។

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សំដៅដល់ការធ្វើផែនការ ប្រើប្រាស់ដីក្នុងឃុំទាំងមូល ទាំងដីរដ្ឋ និងដីឯកជនរបស់បុគ្គលឯកជន ។ ការរៀបចំផែនប្រើប្រាស់ដីក្នុងឃុំមានគោលបំណង :

-រៀបចំផែនការគ្រប់គ្រង និងប្រើប្រាស់ធនធានដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធិភាព និង កាត់បន្ថយទំនាស់ក្នុងការប្រើប្រាស់ដីធ្លី ។

-គាំទ្រកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមប្រកបដោយនិរន្តរភាព និងសមធម៌ ។

-រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

-សំរេចអោយបាននូវការប្រើប្រាស់ដីក្នុងឃុំ ស្របតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលនៃដី ។

-ឆ្លើយតបចំពោះសេចក្តីត្រូវការរបស់អាជ្ញាធរនានា និងរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ។

-ជួយការពារធនធានដី និងធនធានធម្មជាតិផ្សេងៗទៀត មិនអោយបាត់បង់គុណភាពនិង ប្រើប្រាស់អោយចំទិសដៅ ។

-រួមចំណែកគ្រប់គ្រងដីរដ្ឋដែលមានក្នុងឃុំអោយបានល្អប្រសើរតាមតួនាទីជាភ្នាក់ងារតំណាង របស់រដ្ឋ នៅថ្នាក់មូលដ្ឋាន ។

-ស្វែងរកការគាំទ្របច្ចេកទេស ពីស្ថាប័នអង្គភាពនានា និងពីផ្នែកឯកជន ក្នុងការកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគឃុំ ។

ពិនិត្យជារួមការធ្វើផែនការប្រើប្រាស់ដីឃុំនេះ ជាឧបករណ៍មួយដ៏សំខាន់ដែលជួយដល់ក្រុមប្រឹក្សាឃុំ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ ក្នុងការរួមចំណែកដល់ការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចិរភាព និងសមធម៌ ព្រោះ ដីជាកត្តាស្នូលក្នុងការអភិវឌ្ឍន៍ សេដ្ឋកិច្ច ជីវភាពប្រជាពលរដ្ឋ ក្នុងឃុំទាំងមូល ។

ដូច្នេះក្រោយពីបានរៀបចំផែនការប្រើប្រាស់ដីនេះរួច ធ្វើអោយឃុំមានទិសដៅច្បាស់លាស់ក្នុងការធ្វើ ការងារអភិវឌ្ឍន៍ ឬគំរោងសកម្មភាពសំរាប់អាណត្តិរបស់ខ្លួននៅថ្ងៃខាងមុខ មិនត្រឹមតែប៉ុណ្ណោះ វាជាយុទ្ធសាស្ត្រ មួយសំរាប់អាណត្តិបន្តបន្ទាប់រយៈពេល ១៥ ឆ្នាំក្រោយ ដោយផ្អែកលើបញ្ហា មូលហេតុ ដំណោះស្រាយដែលបាន លើកឡើង និងធ្វើការប្រៀបធៀបទៅនឹងលទ្ធផលជាក់ស្តែងដែលបានកើតមានឡើងនៅ ក្នុងឃុំទាំងមូល ។



# ជំពូក១ ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់

## ១.១ ស្ថានភាពទូទៅ

ឃុំអង្កោលមានកំណើតតាំងពីដើមរៀងមកឈ្មោះថា ឃុំភ្នំលាវ គ្រប់សម័យកាលមុន។ ក្រោយមកនៅក្នុងឆ្នាំ ១៩៧៩ រហូតមកដល់ឆ្នាំ ១៩៩៤ ឈ្មោះថាឃុំភ្នំលាវទី២ ក្នុងសម័យរដ្ឋកម្ពុជា ចំណុះឱ្យស្រុកកំពង់ត្រាច ខេត្តកំពត។ បន្ទាប់មកទៀតនៅចុងឆ្នាំ ១៩៩៤ រហូត មកដល់សព្វថ្ងៃមានឈ្មោះថា សង្កាត់អង្កោលចំណុះឱ្យខណ្ឌចំណាក់ចង្អើរ ក្រុងកែប។ ប៉ុន្តែនៅចុងខែកុម្ភៈ ឆ្នាំ ២០០៩ បានប្តូរទៅឃុំអង្កោល ស្រុកចំណាក់ចង្អើរ ខេត្តកែប។

### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| ខេត្ត | កែប | |
| ស្រុក ខណ្ឌ | ដំណាក់ចង្អើរ | |
| ឃុំ សង្កាត់ | ឈ្មោះ: អង្កោល | លេខកូដ: ២៣០១០១ |
| ចំនួន ភូមិ | មាន ៤ ភូមិគឺ : ភូមិអំពែង ភូមិទួលស្រងាំ ភូមិកោះសោម និង ភូមិអង្កោល | |

### ១.១.២ ប្រជាសាស្ត្រ

ចំនួនគ្រួសារ និងប្រជាពលរដ្ឋនៅក្នុង ឃុំ អង្កោល ក្នុងឆ្នាំ ២០០៨ មានចំនួន ១៤៧៥ គ្រួសារ ឯចំនួនប្រជា ពលរដ្ឋមានចំនួន ៧៤២៣នាក់ ការកើនឡើងនេះគួរអោយកត់សំគាល់ជាងនៅឆ្នាំ ២០០៧ ដែលចំនួនប្រជាពលរដ្ឋត្រឹមតែចំនួន ៦៦៦៩នាក់ និងចំនួនគ្រួសារមាន ១៤១៥ គ្រួសារ ។ ហើយមាន ១៤៤១ គ្រួសារ ស្មើរនិង ៩៧,៦៩ភាគរយ ដែលមាន មុខរបរធ្វើស្រែពឹងលើទឹកភ្លៀងជាចំបងដើម្បីចិញ្ចឹមជីវិត ។

<u>តារាងស្ថិតិប្រជាជនឃុំអង្កោល ឆ្នាំ២០០៨ តាមក្រុមអាយុ</u>

| ស្ថិតិតាមក្រុមអាយុ | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម០៥ឆ្នាំ | ៣៧៩ | ៣៥៨ | ៧៣៧ | |
| អាយុ ០៥ឆ្នាំ | ១៦១ | ១៥៣ | ៣១៤ | អាយុចូលរៀនមត្តេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ៦០៧ | ៥៧៣ | ១១៨០ | អាយុចូលរៀនបឋមសិក្សា |
| អាយុពី ១២-១៤ឆ្នាំ | ៣២៧ | ៣២៦ | ៦៥៣ | អាយុចូលរៀនអនុវិទ្យាល័យ |

| | | | | |
|---|---|---|---|---|
| អាយុពី ១៥-១៧ឆ្នាំ | ២៦២ | ២៣៩ | ៥០១ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ៣៤៩ | ៣៦៨ | ៧១៧ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី ២៥-៦០ឆ្នាំ | ១២១៦ | ១៤៣២ | ២៦៤៨ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ៣៦៦ | ៣០៧ | ៦៧៣ | អាយុចូលនិវត្តន៍ |
| ប្រជាជនសរុប | **៣៦៦៧** | **៣៧៥៦** | **៧៤២៣** | |
| ចំនួនគ្រួសារសរុប | ១៤៧៥គ្រួសារ | | | |
| ទំហំគ្រួសារមធ្យម | ៥ នាក់/គ្រួសារ | | | |

### ១.១.៣ ភាពគ្មានដីធ្លី

គ្រួសារដែលធ្វើស្រែគ្មានដីស្រែផ្ទាល់ខ្លួន: ៧៥ គ្រួសារ

គ្រួសារមានដីស្រែតិចជាង ០១ ហិកតា: ១៦០ គ្រួសារ

<u>តារាងចំនួនគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់</u>

| លរ | បរិយាយ | ចំនួនគ្រួសារ | ភាគរយ/ប្រជ.សរុប | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្មានដីស្រែផ្ទាល់ខ្លួន | ៧៥ | % | |
| ២ | មានដីស្រែតិចជាង ១ ហិកតា | ១៦០ | % | |

### ១.១.៤ ស្ថានភាពសេដ្ឋកិច្ច

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | | ផ្សេងៗ |
|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | |
| ១ | មុខរបរកសិកម្ម | | | |
| | - ធ្វើស្រែជាចំបង | ១១៤១ | ៩៧.៦៩ % | |
| | - ដាំដំណាំរយៈពេលខ្លីជាចំបង | ៩៤ | ៦,៣៧ % | |
| | - ដាំដំណាំបន្លែជាចំបង | ១៣ | ០.៨៨ % | |
| | មុខរបរសេវាកម្មជាចំបង | ៣៤ | ២.៣១ % | |
| | មុខរបរនេសាទជាចំបង | ១៨០ | ១២.២០ % | |
| | មុខរបរចិញ្ចឹមសត្វជាចំបង | ១៣ | ០.៨៨ % | |
| <u>ប្រភព</u>: របាយការណ៍ ស្តីពីស្ថានភាព ឃុំអង្កោល ឆ្នាំ ២០០៩ | | | | |

- ប្រជាពលរដ្ឋនៅក្នុងឃុំអង្កោល ប្រមាណ ១១៤១ គ្រួសារ ស្មើរនិង ៩៧.៦៩ % មានមុខរបរធ្វើកសិកម្ម ជាចំបង ។

### ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ

តារាងស្ថិតិសាលា និងសិស្សប្រចាំឆ្នាំ ២០០៨

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រា% មិនចូលរៀន |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារ | សិស្ស | សិស្សស្រី | |
| ថ្នាក់មត្តេយ្យសិក្សា | ១ | ១ | ១ | ៣១៤ | ២៣ | ៨ | ៩៣% |
| ថ្នាក់បឋមសិក្សា | ១០ | ៣៨ | ៣៨ | ១១៨០ | ៧៣៤ | ៣៤៥ | ៣៨% |
| ថ្នាក់អនុវិទ្យាល័យ | 0 | 0 | 0 | ៦៥៣ | ៣៧៧ | ១៥៨ | ៤២% |
| ថ្នាក់វិទ្យាល័យ | 0 | 0 | 0 | ៥០១ | ១៨០ | ៨១ | ៦៤% |
| ... | | | | | | | |

ប្រភព: របាយការណ៍ ស្តីពីស្ថានភាពឃុំអង្កោល ឆ្នាំ ២០០៨

វិស័យអប់រំគឺជាវិសយ័មួយយ៉ាងសំខាន់ ក្នុងការជួយអប់រំបណ្តុះបណ្តាលនូវធនធានមនុស្ស និងផ្តល់ចំណេះដឹងអោយដល់សិស្ស និស្សិត ទូទៅ មិនថាចាស់ ក្មេង ប្រុស ស្រី ឡើយ ។ ហើយក្នុងឃុំអង្កោល ទាំងមូលបច្ចុប្បន្នមានសាលារៀនចំនួន ១១ សាលា ដែលចែក ចេញជា: ថ្នាក់មត្តេយ្យសិក្សា ចំនួន ១ សាលា មានបន្ទប់ចំនួន ១ បន្ទប់ មានថ្នាក់រៀនចំនួន ១ ថ្នាក់ដែលមានសិស្សសរុបចំនួន ២៣ នាក់ ស្រីចំនួន ៨នាក់ មានគ្រូស្រីចំនួន ១ នាក់គត់។ សាលាបឋមសិក្សា ចំនួន ១០ សាលា មានបន្ទប់ចំនួន ៣៨ បន្ទប់ មានថ្នាក់រៀនចំនួន ៣៨ ថ្នាក់ ដែលមានសិស្សសរុបចំនួន ៧៣៤ នាក់ ស្រីចំនួន ៣៤៥នាក់ មានគ្រូចំនួន ៥១ នាក់។ ក្រៅពីសាលា ដែលបានរៀបរាប់ខាងលើនេះក្នុងឃុំក៏នៅ បើកថ្នាក់អក្ខរ:កម្មចំនួន ៣ ថ្នាក់ដែលមានចំនួន ៣ បន្ទប់ សិស្សសរុបចំនួន ៣0នាក់ គ្រូចំនួន ៣នាក់ ឧបត្ថមថវិការដោយរដ្ឋាភិបាល ។

-កុមារដែលគ្រប់អាយុត្រូវចូលរៀននៅថ្នាក់បឋមសិក្សាចំនួន សរុប ១១៨០ នាក់តែចំនួនសិស្សដែលត្រូវចូលរៀននៅថ្នាក់បឋមសិក្សានេះ មានតែ ៧៣៤ នាក់ គឺ មានអត្រាមិនបានចូលរៀន ៣៨ % មូលហេតុមកពី :

១-សិស្សភាគច្រើនមានអាយុលើសពី អាយុ៦ ឆ្នាំ ទើបនិងចូលរៀន និង កុមារមានម្តាយ ឪពុក មានជីវភាពខ្វះខាត ដូចនេះកុមារត្រូវប្រឈមមុខ និងការចេញជួយរករបបផ្សេងៗដើម្បីផ្គតផ្គង់គ្រួសារ។

២-នៅឃុំ អង្កោលគ្មាន អនុវិទ្យាល័យ និង វិទ្យាល័យ ទេ ដូច្នេះ សិស្សដែលត្រូវរៀនបន្ត ត្រូវទៅសិក្សានៅ អនុវិទ្យាល័យ ពងទឹក និង វិទ្យាល័យ ហ៊ុនសែន ចំការដូង ខេត្ត កែប ។

### ១.១.៦ ស្ថានភាពសុខាភិបាល

#### ១.១.៦.១ ផ្នែកសុខាភិបាល

| ល.រ | មណ្ឌល/ប៉ុស្តិសុខភាព | សមត្ថភាពផ្តត់ផ្គង់សេវាកម្ម | | | | |
|---|---|---|---|---|---|---|
| | | ចំនួន | គ្រែ/បន្ទប់ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | មណ្ឌលសុខភាព | ០១ | ៦បន្ទប់, ៥គ្រែ | ០៨នាក់ ស្រី ០៣ | ០៤នាក់ | ០៥នាក់ |

- **<u>១-មណ្ឌលសុខភាព</u> :** គឺជាកន្លែងផ្តល់សេវាអប់រំសុខភាព សេវាថែរទាំជំងឺ និងការព្យាបាលជំងឺជាដើម ក្នុងឃុំអង្គោលទាំងមូលមាន មណ្ឌលសុខភាព ចំនួន ១ ដែលមានទីតាំងស្ថិតនៅតាមដងផ្លូវគ្រួសក្រហមក្នុង ភូមិអំពេង ដែលមាន គ្រូពេទ្យជំនាញចំនួន ៨នាក់ ស្រី ៣នាក់ រងចាំបំរើ សេវាសុខភាពនៅមណ្ឌលសុខភាព នេះ ។ អ្នកជំងឺដែលទៅ ធ្វើការព្យាបាលជំងឺ ពិនិត្យសុខភាពជាមធ្យម ប្រហែល ០៨ ទៅ ១០ នាក់ក្នុង មួយថ្ងៃ ។ បច្ចុប្បន្នដោយសារកំណើនប្រជាជនកើនឡើង ខ្ពស់ តំរូវការហូបចុក ក៏កាន់តែមានសន្ទុះ ខ្ពស់ ដើម្បីបំពេញនៅតម្រូវការនេះ គ្រឿងបរិភោគមួយចំនួន មានការហូរចូលពីប្រទេសជិតខាង ដែលជាហេតុ បណ្តាលអោយមានបញ្ហាផ្នែកសុខភាព កាន់តែមានជំងឺឆ្លងប្លែកៗដែរ ហើយភូមិខ្លះក៏នៅឆ្ងាយ ពីមណ្ឌល សុខភាពជាហេតុនាំអោយ ប្រជាជនយើង ពិបាកក្នុងការទទួលបាននូវសេវាអប់រំសុខភាព ដូចជា ការចាក់ វ៉ាក់សាំងការពារជំងឺ ការផ្សព្វផ្សាយ និង វិធីការពារផ្សេងៗ ។ មណ្ឌលសុភាពឃុំអង្គោល មានផ្តល់សេវា បំរើ ដូចជា: សេវាពិនិត្យ និង ពិគ្រោះជំងឺទូទៅ ការពិនិត្យផ្ទៃពោះ ផ្នែកសម្ភព ចាក់ថ្នាំបង្ការ និង ពិនិត្យ កុមារ កម្មវិធីពន្យាកំណើត និង វះកាត់ខ្នាតតូច (ព្រោះពុំមានឧបករណ៍គ្រប់គ្រាន់) ។
- ចំងាយពីភូមិទៅ មណ្ឌលសុខភាពឃុំ:
  ភូមិអំពែង មានប្រវែង ១ គីឡូម៉ែត្រ ភូមិទួលសាងាំ ១.៥គីឡូម៉ែត្រ ភូមិ កោះសោម ១៥ គីឡូម៉ែត្រ និង ភូមិអង្គោល ៣ គីឡូម៉ែត្រ ។ ដូច្នេះចំងាយជាមធ្យមពីភូមិទៅមណ្ឌលសុខភាពឃុំ: ៥.១២៥ គីឡូម៉ែត្រ។
- សេវាកម្មសុខភាពនៅក្នុងឃុំអង្គោលមិនទាន់គ្រប់គ្រាន់ដើម្បីបំរើសេវាសុខភាពរបស់ប្រជាជននៅឡើយទេ មូលហេតុ : ប្រជាជនរស់នៅដាច់ឆ្ងាយពីគ្នា និងមានចំងាយផ្លូវឆ្ងាយពីមណ្ឌលសុខភាពឃុំ បណ្តាលអោយ មានការលំបាកក្នុងការធ្វើដំណើរក្នុងការដឹកអ្នកជំងឺដោយម៉ូតូ ហើយការផ្តល់សេវាផ្នែកសុខភាព មិនទាន់គ្រប់គ្រាន់នៅឡើយ ព្រោះពុំមានឧបករណ៍ និង ថ្នាំព្យាបាលគ្រប់គ្រាន់។


មណ្ឌលសុខភាព អង្គោល
ANGKOUL HEALTH CENTER


Water and Sanitation Project
Toulsa ngam Village, Angkul Commune
Damnakchangeur District, Kep municipality
• Direct Beneficiaries : People living in Toulsa ngam Village, Angkul Commune, Damnak changeur District, Kep municipality
• Funded by NZRC through Federation
• Implemented by Kep Red Cross Branch, Year 2005
RED CROSS

## ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | | សំគាល់ |
|---|---|---|---|---|---|---|
| | | សរុប | ប្រើបានពេញ១ឆ្នាំ | ប្រើមិនបាន១ឆ្នាំ | ខូចខាត | |
| ១ | អណ្តូងស្នប់ | ២១ | ១៤ | ៧ | | គ្មានទឹកនៅរដូវប្រាំង |
| ២ | អណ្តូងលូ | ២៣ | ៩ | ១៤ | | គ្មានទឹកនៅរដូវប្រាំង |
| ៣ | ស្រះ | ៤១ | ៩៣ | ៣២ | | គ្មានទឹកនៅរដូវប្រាំង |

ប្រភព: របាយការណ៍ ស្តីពីស្ថានភាពឃុំពងទឹក ឆ្នាំ ២០០៩

- ថ្វីបើចំនួនប្រភពទឹកស្អាតមានមួយចំនួនក៏ពិតមែន ប៉ុន្តែដោយសារពុំមានថវិកាសំរាប់ថែទាំ និងជួសជុលជាបណ្តើរ១ បានធ្វើអោយអណ្តូងមួយចំនួនខូច និងស្រះមួយចំនួនទៀតរីងរាក់ប្រើ មិនកើតនៅរដូវប្រាំង។ ហេតុដូច្នេះទាមទារអោយមានការជីក ស្តារ អណ្តូង ស្រះថ្មីបន្ថែមមួយចំនួនទៀត ដើម្បីធានាអោយបាននូវការផ្គត់ផ្គង់ទឹកស្អាត សំរាប់ប្រើប្រាស់ទៅតាមសេចក្តីត្រូវការរបស់ប្រជាជន។



**ពាងយក្សសំរាប់ស្តុកទឹកភ្លៀង**

## ១.២ ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

ឃុំនេះមានផ្ទៃដី ៣២៦៨ ហិចតា មានទីតាំងសាលាឃុំស្ថិតនៅក្នុង ភូមិអំពែង មានចំងាយប្រហែល ៤គីឡូម៉ែត្រ ពីសាលាស្រុក ដំណាក់ចង្អើរ ។ មានព្រំប្រទល់:

- ខាងជើងទល់និង ឃុំ ពងទឹក
- ខាងត្បូងទល់និង ឆ្នេរអង្កោល
- ខាងកើតទល់ ឃុំ ស្វាយទង ស្រុកកំពង់ត្រាច
- ខាងលិចទល់និង ឃុំ ពងទឹក




### ១.២.២ អាកាសធាតុ

កំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ: ២៨៥០ មម

រយៈពេលនៃរដូវប្រាំង: ០៦ ខែ ពីខែមករា ដល់ខែ មិថុនា ។

### ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន

| ល | ប្រភេទផ្លូវ | ស្ថានភាព និងប្រវែងផ្លូវ (ម) | | សំគាល់ |
|---|---|---|---|---|
| | | ប្រវែងសរុប | ប្រវែងខូចខាត | |
| ១ | ផ្លូវក្រាលកៅស៊ូ | 0 | | |
| ២ | ផ្លូវក្រាលគ្រួសក្រហម | ២៥២៩0 | | |
| ៣ | ផ្លូវលំដីស | ៩000 | | |
| ៤ | ផ្លូវរទេះ | ១៨000 | | |

ប្រភព: ប្រជុំធ្វើបច្ចុប្បន្នភាពជាមួយក្រុមប្រឹក្សាឃុំ /គណៈកម្មាធិការកសាងផែនការ និងថវិកា ខែ.មិថុនា ឆ្នាំ២០០៩




**ផ្លូវក្រាលកៅស៊ូ :** នៅក្នុងឃុំអង្កោល ពុំមានផ្លូវក្រាលកៅស៊ូទេ តែឃុំកំពុងធ្វើគម្រោងស្នើរសុំ ។

**ផ្លូវគ្រួសក្រហម :** ផ្លូវប្រៀបដូចជាសសៃឈាមដែលរាយខ្វាត់ខ្វែងពាសពេញ ភូមិ ឃុំ សំរាប់ធ្វើចរាចរ ដឹក ជញ្ជូនទំនិញកសិផល ទៅកាន់ទីផ្សារ និង សំរាប់ធ្វើការទំនាក់ទំនងពីមួយទៅមួយតាមរយៈការធ្វើចរាចរ លើផ្លូវនេះឯង នៅក្នុងឃុំអង្កោល ទាំងមូលមានផ្លូវក្រាលគ្រួសក្រហមចំនួន ៧ ខ្សែ ដែលកាត់ពីភូមិ មួយទៅភូមិមួយ ដែលមាន ប្រវែងសរុប ២៥២៥០ ម៉ែត្រ ។ ក្នុងចំណោមផ្លូវទាំង ៧ ខ្សែនេះ ក្នុងឃុំមានផ្លូវគ្រួសក្រហមសំខាន់ ១ខ្សែ សំរាប់ចរាចរពីឃុំមួយទៅកាន់ ឃុំមួយទៀត ដឹកជញ្ជូនទំនិញពីប្រទេសវៀតណាម និង ដឹកជញ្ជូនទំនិញកសិផលទៅកាន់ទីផ្សារ ។ ផ្លូវគ្រួសក្រហមខ្សែទី១ ចាប់ពីភូមិភ្នំលាវ ទៅកំពង់ត្រាច កាត់តាមភូមិអំពែង និងភូមិអង្កោល មានប្រវែង ៩០០០ម៉ែត្រ ដែលរងការខូចខាត ដោយសារការដឹកជញ្ជូនទំនិញ កសិផលលើសចំណុះ ឬ ទំងន់ផ្ទុកយានយន្តធ្ងន់ៗ របស់ឈ្មួញ ចេញចូលពីប្រទេសវៀតណាម ហើយកំពុងតែជួសជុលថ្មី។ ខ្សែទី២ ក្នុងភូមិអំពែង ដែលមានប្រវែង ២២៥០ម៉ែត្រផ្លូវធ្វើដំណើរដឹកផលិតផលកសិផល ក្នុងភូមិ ។ ខ្សែទី៣ ក្នុងភូមិអង្កោល ដែលមានប្រវែង ២០០០ម៉ែត្រផ្លូវនេះខូចខាតដោយសារទឹកហូរច្រោះដោយភ្លៀងច្រើន ។ ខ្សែទី៤ ចាប់ពីភូមិសំរោងតភ្ជាប់ទៅភូមិទូលស្រងាំ ឆ្ពោះទៅភូមិព្រៃតាកុយ ដែលមានប្រវែង ៦៦០០ម៉ែត្រ ខូចខាតស្ទើរទាំងស្រុង ដោយរថយន្តដឹកធ្ងន់ និង ទឹកភ្លៀងហូរច្រោះ។ ខ្សែទី៥ ចាប់ពីពាក់កណ្តាលភូមិទូលស្រងាំ មកទល់នឹងទំនប់អូរថ្ម ភូមិព្រៃតាកុយ ។ ដែលមានប្រវែង ២៤០០ម៉ែត្រ ខូចខាតដោយអន្លើរៗ ។ ខ្សែទី៦ ចាប់ពីភូមិអង្កោល ដែលមានប្រវែង ១៧៥០ម៉ែត្រ ខូចខាតខ្លះៗ ដោយសារការដឹកជញ្ជូនផលកសិកម្ម និង ការហូរច្រោះ។ ខ្សែទី៧ ចាប់ពីភូមិកោះសោម ដែលមានប្រវែង ១២៥០ម៉ែត្រ ខូចខាតខ្លះៗ ដោយសារទឹកហូរពីលើភ្នំ និងមានភ្លៀងធ្លាក់ច្រើន ។

**ផ្លូវលំសរុបៈ** ក្នុងឃុំអង្កោលមានផ្លូវលំ សរុបចំនួន ៤ខ្សែ ដែលមានប្រវែងសរុបស្មើនឹង ៩០០០ម៉ែត្រ ហើយផ្លូវទាំងអស់នេះ តភ្ជាប់ចេញ ពីផ្លូវគ្រួសក្រហមចូលទៅ តាមភូមិនីមួយៗ ដែលមានសារៈសំខាន់ សំរាប់ធ្វើដំណើរចេញចូលពីភូមិមួយទៅភូមិមួយ និងពីភូមិ ទៅស្រែ និងពីស្រែទៅកាន់កន្លែងផ្សេងៗទៀត ក៏ដូចជាការដឹកជញ្ជូននូវទំនិញកសិផលផ្សេងៗចេញពីភូមិដើម្បី យកទៅកាន់ទីផ្សារ ។ មានផ្លូវលំទាំងអស់បានរងនូវការខូចខាតស្ទើរទាំងស្រុង ដោយពិបាកក្នុងការធ្វើចរាចរទៅមក នេះដោយសារការពុំយកចិត្តទុកដាក់ក្នុងការថែទាំផ្លូវ ពីសំណាក់បងប្អូនប្រជាពលរដ្ឋ ទឹកហូរកាត់ផ្លូវ និងការដឹកជញ្ជូនទំនិញកសិផលលើសចំណុះ ។

**ផ្លូវរទេះសរុបៈ** ផ្លូវរទេះក៏មានសារៈសំខាន់ដូចផ្លូវគ្រួសក្រហម និងផ្លូវលំដែរ តែទាស់ត្រង់ថាផ្លូវរទេះ មិនបាន លើកចាក់បំពេញដីស ឬ ក្រហម ក៏ដោយ គឺមានសារៈសំខាន់ក្នុងការចរាចរ របស់បងប្អូនប្រជាកសិករក្នុងការដឹកជញ្ជូន កណ្តាប់ស្រូវ ពីស្រែមួយទៅស្រែមួយ ពីភូមិមួយ ទៅភូមិមួយ និងពីភូមិទៅកាន់កន្លែងផ្សេងៗទៀត ការធ្វើចរាចរពី ភូមិទៅព្រៃដើម្បីរកអុស រកថ្នាំបូរាណ រកអនុផលព្រៃឈើផ្សេងៗ ។ ផ្លូវរទេះសរុប ចំនួន ៩ខ្សែ ស្មើនឹង ១៨០០០ម៉ែត្រ ។

## ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

ការប្រើប្រាស់ដីនៅក្នុងឃុំអង្កោលអាចចែកចេញជា ៦ ចំណាត់ថ្នាក់សាមញ្ញ រួមមាន : ដីលំនៅដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធ ដីកសិកម្ម(ស្រែវស្សា ស្រែប្រាំង និងដីចំការ) ព្រៃកោងកាង ដីប្រឡាយ ទំនប់ ព្រៃក ដីស្រែអំបិល និងព្រៃគុម្ពោធ និង ដីស្មៅ ។



តារាងចំណាត់ប្រភេទនៃការប្រើប្រាស់ដីសាមញ្ញបច្ចុប្បន្ន

| ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមបច្ចេកទេស) | ទំហំ ( ហត) | ចំណាត់ថ្នាក់ប្រើប្រាស់ដី (តាមមូលដ្ឋាន) |
|---|---|---|
| ផ្ទៃដីលំនៅដ្ឋាន និង ហេដ្ឋារចនាសម្ព័ន្ធ | ៤១៧ | ភូមិករ ភូមិឋាន |
| **ដីកសិកម្ម** | ១៤២៥ | ដីស្រែ |
| ផ្ទៃដីស្រែអំបិល | ៤៦៨ | |
| ព្រៃកុម្ពោធ និង ដីស្មៅ | ៩១ | |
| ផ្ទៃដីប្រឡាយ ទំនប់ និង ព្រែក | ៣០ | ប្រភពទឹក |
| ដីព្រៃកោងកាង | ៨៣៧ | |
| **ដីព្រៃ/គំរបព្រៃ:** | ១.៥០ | |

តារាងប្រភេទនៃការប្រើប្រាស់ដីលំអិត

| លរ | ប្រភេទនៃការប្រើប្រាស់ដី | ទំហំ ( ហត) | ចំណាត់ថ្នាក់មូលដ្ឋាន |
|---|---|---|---|
| ១ | ដីលំនៅដ្ឋានភូមិ | ៤១៧ | ផ្ទះ-ទីសំណាប-ឈើហូបផ្លែ |
| ២ | ដីស្រែវស្សា | ៨៣០.៤៥ | ធ្វើស្រែវស្សា-ស្រែប្រាំង |
| ៣ | ដីស្រែលាយភូមិ | ៩៩៥ | |
| ៤ | ដីចំការដំណាំ | ៨ | ឈើហូបផ្លែ-ដំណាំរយ:ពេល ខ្ចីពោត...-បន្លែគ្រប់មុខ |
| ៥ | ផ្ទៃដីស្រែអំបិល  បង្គា | ៤៦៨ | |
| ៦ | ព្រៃកុម្ពោធ | ៤៧.៥០ | |
| ៧ | ដីព្រៃកោងកាង | ៨៣៧ | |
| ៨ | ព្រៃស្រោង( សើម) | ១.៥០ | |
| ៩ | ចំការបោះបង់ដុះស្មៅ | ៤៤ | |
| ១០ | ប្រភពទឹក | ៣០ | |
| | ផ្ទៃសរុប | ៣២៦៨ | |

ប្រភព: ប្រជុំធ្វើបច្ចុប្បន្នភាពជាមួយគណ:កម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ ថ្ងៃទី.....ខែ.....ឆ្នាំ.....

### ១.៣.២ ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី

- **ដីលំនៅដ្ឋានភូមិ(ដីភូមិ):**គឺជាដីភូមិដែលប្រជាជនយើងរស់នៅកន្លែងតំបន់ដីទួលមិនលិចទឹកនៅ រដូវវស្សា ហើយ ដែល លំនៅដ្ឋាន ខ្លះជា លក្ខណៈប្រមូលផ្តុំគ្នា ជាទីប្រជុំជន មានជួររបងកំណត់ត្រឹមត្រូវ ពីចំងាយរបង ទៅអក្ស័ផ្លូវដែល ប្រជាជនយើងកំណត់ធ្វើ តាមគ្នាហើយដែលរស់នៅអមសងខាងផ្លូវ លំនៅដ្ឋាន ខ្លះទៀត ដែលមានជា លក្ខណៈរស់នៅដោយ រាយប៉ាយ ដោយដាច់ៗពីគ្នាមិនមានការ កំណត់ជួរត្រឹមត្រូវ មុខក្រោយ។ ដីតំបន់លំនៅដ្ឋាននេះប្រជាជនយើង ចូលចិត្តដាំដំណាំឈើហូបផ្លែ មានដូចជា ដូង ស្វាយ ទៀប ខ្នុរ ជាដើម និង មានដាំដំណាំ រួមផ្សំខ្លះៗ ទៀតនៅតាមភូមិដ្ឋានរបស់ពួកគាត់ដើម្បី បរិភោគប្រចាំថ្ងៃ ។ លំនៅដ្ឋាននៅ ក្នុងតំបន់ទីប្រជុំជនភាគច្រើន ជាផ្ទះប្រភេទឈើលើថ្មក្រោម ដំបូលប្រកក្បឿង ជញ្ជាំង ក្តារ និង រៀបឥដ្ឋថ្ម ចាក់ប៉េតុងពីក្រោម ហើយលំនៅដ្ឋានផ្សេងទៀតជាប្រភេទ ឈើប្រក់សង្កសី និង ក្បឿងខ្លះៗ តែមិន បានរៀប ឥដ្ឋ ថ្ម ពីក្រោម ដែលមានទំហំដីចាប់ពី ទទឹង១០ ទៅ ១៥ម៉ែត្រ បណ្តោយពី ២៥ ទៅ ៣០ ម៉ែត្រ ដែលដី ភូមិលាយជាមួយលំនៅដ្ឋាននេះមានផ្ទៃដី សរុប ក្នុងឃុំអង្គោល ទាំងមូលមាន ៤១៧ហិចតា ។ ឆ្លងតាមការ ដែលបានរៀបរាប់ខាងលើយើងអាចធ្វើការសន្និដ្ឋានបានថា ដីលំនៅដ្ឋានដែលប្រជាជន យើងធ្វើលំនៅដ្ឋាន រាល់ថ្ងៃនេះ មានលក្ខណៈជាការប្រមូលផ្តុំគ្នា ឬ ជាទីប្រជុំជន ដើម្បីងាយស្រួល ក្នុងការទំនាក់ទំនងគ្នា។ ដីដែលប្រជាជនយើងយកធ្វើជាលំនៅដ្ឋាន ភាគច្រើនជាប្រភេទដីទួលខ្ពស់ៗ មិនអាច យកទៅប្រើប្រាស់ធ្វើ ជាស្រែបាន ឡើយក្រៅពីធ្វើជាដីលំនៅដ្ឋាន ហើយទៅថ្ងៃអនាគត ប្រជាជន យើង និង ធ្វើការពង្រីកភូមិដ្ឋាន របស់គាត់ជាបន្តទៀត ដោយគាត់គិតថា និងពង្រីកដីស្រែដែលនៅក្បែរៗដីភូមិរបស់ គាត់ ដើម្បីអោយកូនចៅ ជំនាន់ក្រោយរបស់គាត់បានរស់នៅ។
- **ដីភូមិលាយដីស្រែ:** គឺជាដីទំនាប ប្រភេទដីល្បាយខ្សាច់ ភាគច្រើនប្រជាជនទាំគ្នាដាំ ដំណាំដូចជា: ត្រឡាច ល្ពៅ ត្រសក់ ឪឡឹក ។ល។ ដែលប្រជាជនយើងបានបែកលំនៅដ្ឋានថ្មី ដោយពួកគាត់មានគូរ ស្រករ ឬ គ្រួសារថ្មី ហើយមាន ការខ្វះខាតដីសំរាប់ធ្វើលំនៅដ្ឋាន ពួកគាត់ក៏បានយកដីស្រែសំរាប់ធ្វើជាដី លំនៅដ្ឋានថ្មី របស់ពួក គាត់ ដោយបានចាក់ដីបំពេញរាងរាល់ឆ្នាំ បន្តិចម្តងៗ រហូតដល់ពួកគាត់អាចរស់នៅ និង តាំងទីលំនៅថ្មីបាន ដោយរស់នៅ រតេតរតូត គ្មានជួរ ដោយសង់ជាប្រភេទឈើ សរសរមូល ដំបូលប្រកសង្កសី ស្លឹក និងក្បឿងខ្លះៗ សង់ផុតពីដីតាមបែប ទំនៀមទំលាប់បូរាណ ។ ឆ្លងតាមការប្រមូល ទិន្នន័យបានឆ្លុះបញ្ចាំង អោយ ឃើញថាតាម ភូមិនីមួយៗប្រជាជនដែល មានគូរស្រករថ្មី បែកលំនៅដ្ឋានថ្មី គឺពួកគាត់តែងតែយកដី ស្រែធ្វើជាលំនៅដ្ឋាន ដូច្នេះវាធ្វើអោយមានការប៉ះពាល់យ៉ាងខ្លាំងទៅលើការខ្វះខាត ស្បៀង សំរាប់ការ ហូបចុកក្នុងគ្រួសារ ។

- **ព្រៃស្រោង:** ជាប្រភេទព្រៃដែលលាតសន្ធឹងតាមបណ្តោយជួរភ្នំ អង្កោល លើផ្ទៃដីប្រមាណ ១.៥០ហិចតា ដែលព្រៃនេះ ជាជំរកសត្វព្រៃ មានសត្វច្រើនប្រភេទ រស់នៅ ដូចជា: សត្វ ទន្សាយ សត្វ ចំពោច ពស់ សត្វ ជ្រូកព្រៃ និងសត្វស្លាប ។ល។ ព្រៃនៅតំបន់នោះឥឡូវនេះបានរីចរាល់ស្ទើតែអស់ទៅហើយ ព្រោះមានការ ទន្ទ្រាន ពីប្រជាពលរដ្ឋ ។
- **ដីព្រៃកោងកាង** : ជាប្រភេទដីល្បាប់ភក់ខ្មៅ ហើយលិចទឹកប្រចាំ។ ព្រៃកោងកាងជាប្រភេទ ព្រៃលិចទឹក ដុះនៅតំបន់សមុទ្រ វាផ្តល់ជំរក ចំណី និង កន្លែងបង្កកំណើត សំរាប់សត្វមានជីវិតគ្រប់ប្រភេទៗ ដែលរស់នៅក្នុងទឹក។
- **ផ្ទៃដីស្រែអំបិល:** ជាប្រភេទដីល្បាប់ភក់ លាយខ្សាច់ នៅជិតសមុទ្រ តែមិនលិចទឹក ។ រៀងរាល់នៅខែ សីហា និង កញ្ញា ឬអាចដល់ខែ តុលា រហូតមេឃអស់ភ្លៀង គេចាប់ផ្តើមជីកប្រឡាយដើម្បីបង្ហូរទឹកប្រៃចូល (ជីកកិញ) លើកភ្លឺទប់ទឹក និង បង្ហាប់ដីអោយណែនល្អ ជាមុនសិន ទើបបញ្ចូលទឹកប្រៃចូល ទុកហាលចោល រយៈពេល ១៥ ថ្ងៃ ទើបប្រមូលផលលើកទី ១ ក្រោយមក រយៈពេល ៧ ថ្ងៃ ប្រមូលជាបន្តបន្ទាប់។ គេឈប់ ធ្វើស្រែអំបិល នៅពេលមានភ្លៀងធ្លាក់មក ព្រោះវានាំអោយទឹកសមុទ្រសាប មិនអាចកកជាអំបិល បាន។
- **ផ្ទៃដីស្រែ:** ប្រជាជននៅក្នុងឃុំអង្កោល ស្ទើរតែ ៩៨ ភាគរយ ជាកសិករ ដែលប្រកបរបរកសិកម្ម និង ចិញ្ចឹមសត្វ សំរាប់ជួយផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ។ ផ្ទៃដីស្រែមាន ប្រមាណ ១៤២៥ ហិកតា ដែលភាគច្រើន ជាប្រភេទដី ល្បាយខ្សាច់ និង ដីខ្មៅ ។ ទិន្នផលស្រូវជាមធ្យម ២ តោន។ ប្រជាជនភាគច្រើននៅក្នុងឃុំ ធ្វើស្រែតែមួយដងគត់ ក្នុងមួយឆ្នាំ នៅពេល ច្រូតកាត់រួចរាល់គាត់ទុកដីស្រែទំនេរ ចោល ដោយមិនបាន ធ្វើស្រែប្រាំងបន្តទៀត ព្រោះគ្មានប្រភពទឹករងចាំ រដូវវស្សាមានភ្លៀងធ្លាក់ទើបពួកគាត់ ធ្វើស្រែ បន្តទៀត ។ ឆ្លងតាមការសាកសួរពីមេភូមិ និងក្រុមប្រឹក្សាឃុំបានបញ្ជាក់អោយឃើញថា ទៅថ្ងៃមុខដីស្រែនឹងត្រូវទទួលរង នូវផលប៉ះពាល់ យ៉ាងខ្លាំង ដែលអាចធ្វើ អោយដីខ្សោះជីជាតិ ទិន្នផលស្រូវទាប ប្រឈមមុខ និង ការខ្វះខាត ស្បៀង ។

**ប្រភពទឹក:** ក្នុង ឃុំអង្កោលទាំងមូល មានបឹងទឹកប្រៃ ចំនួន១ ដែលបឹងនេះមានទំហំ ៧0 ហិចតា។ មានព្រែក ចំនួន២ ដែលមានប្រវែង ៦,៥គីឡូម៉ែត្រ និង មានអូរចំនួន១ ដែលមានប្រវែង ១,៥ គីឡូម៉ែត្រ។

### ១.៣.៣ ផលិតកម្មកសិកម្ម

ប្រជាជននៅក្នុងឃុំអង្កោល ស្ទើរតែ ៩៨ ភាគរយ ជាកសិករ ដែលប្រកបរបរកសិកម្ម និង ចិញ្ចឹមសត្វ សំរាប់ជួយផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ។ ផ្ទៃដីស្រែមាន ប្រមាណ ១៤២៥ ហិកតា ដែលភាគច្រើន ជាប្រភេទដី ល្បាយខ្សាច់ និង ដីខ្មៅ ។ ទិន្នផលស្រូវជាមធ្យម ២ តោន។ ប្រជាជនភាគច្រើននៅក្នុងឃុំ

ធ្វើស្រែតែមួយដងគត់ ក្នុងមួយឆ្នាំ នៅពេល ច្រូតកាត់រួចរាល់គាត់ទុកដីស្រែទំនេរ ចោល ដោយមិនបាន ធ្វើស្រែប្រាំងបន្តទៀត ព្រោះគ្មានប្រភពទឹករងចាំ រដូវវស្សាមានភ្លៀងធ្លាក់ទើបពួកគាត់ ធ្វើស្រែ បន្តទៀត ។ ឆ្លងតាមការសាកសួរពីមេភូមិ និងក្រុមប្រឹក្សាឃុំបានបញ្ជាក់អោយឃើញថា ទៅថ្ងៃមុខដីស្រែនឹងត្រូវទទួលរង នូវផលប៉ះពាល់ យ៉ាងខ្លាំង ដែលអាចធ្វើ អោយដីខ្សោះជីជាតិ ទិន្នផលស្រូវទាប ប្រឈមមុខ និង ការខ្វះខាត ស្បៀង ។

តារាងប្រភេទដំណាំកសិកម្ម សំខាន់ៗ និងទិន្នផលទទួលបាន

| ល.រ | ប្រភេទកសិកម្ម | ផ្ទៃដី (ហត) | | ផល/ទិន្នផល |
|---|---|---|---|---|
| | | សរុប (ហត) | ទិន្នផល (ត/ហត) | ផលសរុប (តោន) |
| ១ | ដំណាំស្រូវវស្សា | ៨៧៧ | ២ | ១៧៥៤.៦៦ |
| ២ | ដំណាំដំឡូងជ្វា | ១៧.៥ | ២.៥ | ៤៣.៨ |
| ៣ | ដំណាំពោត | ៦ | ០.៩ | ៥.៤ |

## ១.៣.៤ ធនធានធម្មជាតិ

### ១.៣.៤.១ ធនធានព្រៃឈើ

ជាប្រភេទព្រៃដែលលាតសន្ធឹងតាមបណ្តោយជួរភ្នំ អង្កោល លើផ្ទៃដីប្រមាណ ១.៥០ហិចតា ដែលព្រៃនេះ ជាជំរកសត្វព្រៃ មានសត្វច្រើនប្រភេទ រស់នៅ ដូចជា: សត្វ ទន្សាយ សត្វ ចំពោច ពស់ សត្វ ជ្រូកព្រៃ និង សត្វស្លាប ។ល។ ព្រៃនៅតំបន់នោះឥឡូវនេះបានរីចរាល់ស្ទើតែអស់ទៅហើយ ព្រោះមានការ ទន្ទ្រាន ពីប្រជាពលរដ្ឋ ។ ព្រៃ កោងកាង ជាប្រភេទឈើដែលដុះក្នុងល្បាប់ភក់ខ្មៅ ហើយលិចទឹកប្រចាំ។ ព្រៃកោងកាង ជាប្រភេទ ព្រៃលិចទឹក ដែលវាដុះនៅតំបន់សមុទ្រ វាផ្តល់ជំរក ជាចំណី និង កន្លែងបង្កកំណើត សំរាប់សត្វមានជីវិត គ្រប់ប្រភេទៗ ដែលរស់នៅក្នុងទឹក។




### ១.៣.៤.២ ធនធានជលផល

ដោយឃុំអង្កោល ស្ថិតនៅតាមតំបន់ឆ្នេរ ធ្វើឱ្យតំបន់នេះសំបូរធនធានជលផលសមុទ្រ ដែលមានប្រភេទត្រី ពពួកគ្រំ គ្រែង ងាវ ខ្យង ផ្កាថ្ម ស្មៅសមុទ្រ ដែលជាជំរកលាក់ខ្លួន និងពងកូនរបស់ត្រីគ្រប់ប្រភេទ។ ដើម្បីធ្វើឱ្យធនធានជលផលកាន់តែប្រសើរឡើង ឃុំព្រមទាំងប្រជាពលរដ្ឋបានមូលមតិគ្នា បង្កើតជាសហគមន៍ការពារព្រៃកោងកាងដោយមានការគាំទ្របច្ចេកទេសពីរដ្ឋបាលជលផល ហើយបច្ចុប្បន្ននេះដោយមានការខិតខំ គណៈកម្មាការគ្រប់គ្រងសហគមន៍ និងសមាជិកសហគមន៍ទាំងអស់ដែលស្ថិត នៅក្នុងភូមិ បានចូលរួមការពារថែរក្សា ពីសំណាក់បងប្អូនប្រជាពលរដ្ឋ ក្មេង ចាស់ ប្រុស ស្រី នៅក្នុងភូមិ និងក្រៅភូមិដោយមិន អោយមានការរុករានព្រៃ និង សត្វមានជីវិតគ្រប់ប្រភេទ ដើម្បីធានាធនធានជលផលទុកប្រើប្រាស់នៅក្នុងឃុំទាំងមូល ដែលសហគមន៍នេះមានផ្ទៃដីប្រមាណ ១០ ហិកតា ។



ផ្កាថ្មនៅតំបន់ឆ្នេរអង្កោល

## ១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល

### ១.៤.១ ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

តំលៃកសិផល ផល អនុផលព្រៃឈើ និង ផលនេសាទ ប្រែប្រួលតាមរដូវកាល និង តម្រូវការប្រើប្រាស់ ដូចតារាងបង្ហាញជូនខាងក្រោមៈ

**តំលៃផលនេសាទតាមបណ្តាឆ្នាំ**

| បរិយាយ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ |
|---|---|---|---|---|
| ក្តាមសេះ | ២០០០០ | ២៥០០០ | ៣០០០០ | ៣៨០០០ |
| បង្គាលេខ ១ | ២០០០០ | ២៥០០០ | ៣០០០០ | ៣៥០០០ |
| បង្គាលេខ ២ | ១៦០០០ | ១៨០០០ | ២០០០០ | ២៥០០០ |
| បង្គាលេខ ៣ | ៨០០០ | ១០០០០ | ១៣០០០ | ១៧០០០ |

| | | | | |
|---|---|---|---|---|
| ត្រីលេខ១ | ៧០០០ | ១០០០០ | ១៣០០០ | ១៥០០០ |
| ត្រីលេខ២ | ៥០០០ | ៦០០០ | ៧០០០ | ១២០០០ |
| ត្រីលេខ៣ | ៤០០០ | ៥០០០ | ៦០០០ | ៨០០០ |
| ត្រីតុកកែ | ២៥០០០ | ៣០០០០ | ៣៥០០០ | ៤៥០០០ |
| មឹក | ១០០០ | ១២០០ | ១៥០០០ | ២០០០០ |
| មឹកពីងពាង | ៧០០០ | ១០០០០ | ១៣០០០ | ១៥០០០ |
| ត្រីជី | ៧០០ | ១០០០ | ១៥០០ | ១៧០០ |

ឯកត្តា ១គក្រ/រៀល

តំលៃទីផ្សារ ផល អនុផលព្រៃឈើ

| **ផលពៃឈើ** | **$ម^{៣}$** | **តំលៃ (ដុល្លារ)** | **ផ្សេងៗ** |
|---|---|---|---|
| ឈើលេខ ១ | ១ | ៦០០-៧០០ | នាំចូលពីក្រៅ ដោយក្រុមហ៊ុន |
| ឈើលេខ ២ | ១ | ៤០០-៥០០ | នាំចូលពីក្រៅ ដោយក្រុមហ៊ុន |
| ឈើលេខ ៣ | ១ | ២៥០-៣០០ | នាំចូលពីក្រៅ ដោយក្រុមហ៊ុន |
| ឈើក្រៅលំដាប់ | | | |
| អនុផលព្រៃឈើ | ឯកត្តា | តំលៃ (រៀល) | ផ្សេងៗ |
| បង្គោលរបង | ១ ដ | ៨០០០-១០០០ | លក្ខណៈឯកជនពីក្រៅ |
| ធ្យូង | ១គក្រ | ៥០០-៧០០ | លក្ខណៈឯកជនពីក្រៅ |

តម្លៃស្រូវតាមបណ្តាឆ្នាំ

| **លំដាប់តំលៃ** | **២០០៦** | **២០០៧** | **២០០៨** |
|---|---|---|---|
| តម្លៃលក់ស្រូវខ្ពស់បំផុត | ៦០០ | ៨៦០ | ៨០០ |
| តម្លៃលក់ស្រូវមធ្យម | ៥៥០ | ៨១០ | ៧០៨ |
| តម្លៃលក់ស្រូវទាប | ៥០០ | ៧៦០ | ៦១៧ |

ឯកត្តា ១គក្រ/រៀល

## ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល

ឃុំអង្កោល មានផលិតផលកសិផលចំបង ដូចជា ស្រូវ ដំឡូងមី ដំឡូងជ្វា និង ផលនេសាទសមុទ្រ ដែលជាប្រភពចំណូលប្រចាំថ្ងៃ និង ប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋ។ ក្រៅពីទុកបរិភោគ ពួកគាត់បានយក ផលិតផលទាំងនោះទៅលក់ ដើម្បីទិញ និង ដោះដូរជារបស់ប្រើប្រាស់ផ្សេងៗ។ ខាងក្រោមនេះគឺជាខ្សែសង្វាក់និង ចរាចរផលិតផល :

**ឈ្មួញក្រៅស្រុកៈ**

- រៀងរាល់រដូវប្រមូលស្រូវមកដល់ តែងតែមានឈ្មួញវៀតណាមមកទិញដុំ និង រាយដល់ទីកន្លែងផ្ទាល់ពីប្រជាពលរដ្ឋ ចំពោះតំលៃគឺអនុឡោមតាមតំលៃទីផ្សារ។ ក្រៅពីនេះមានការទិញផងដែលនូវផលនេសាទ និង កសិផលផ្សេងៗទៀត។
- ប្រជាពលរដ្ឋទិញពីឈ្មួញវៀតណាមវិញនៅសំភារៈ គ្រឿងឧបភោគ បរិភោគ និង ជីកសិកម្ម ។

**ឈ្មួញក្នុងស្រុកៈ**

- មានឈ្មួញភាគច្រើនមកពី ខេត្តកំពត មកទិញដំឡូងជ្វា ពីប្រជាពលរដ្ឋ ដល់ទីកន្លែងដោយផ្ទាល់ទៅតាមតំលៃទីផ្សារ ដូចខាងក្រោមៈ

  -ដំឡូងជ្វា ក្នុង១តោន តំលៃពី ៦៥០០០រៀល ទៅ ៨០០០០រៀល

## ១.៤.៣ ឱកាស ឧបសគ្គ

នៅក្នុង ឃុំអង្កោល មានឆ្នេរខ្សាច់ពណ៌សដ៏ស្អាត និង ទិដ្ឋភាពផ្ទៃសមុទ្រពណ៌ខៀវស្រងាត់ មានធម្មជាតិជុំវិញស្រស់បំព្រង ជាទីគយគន់របស់ភ្ញៀវទេសចរណ៍ជាតិ និង អន្តរជាតិដែលមកកំសាន្ត ។ ក្រៅពីនេះ ក៏មានធនធានធម្មជាតិ ដ៏មានតំលៃមួយទៀតដែរ ដូចជាព្រៃកោងកាង ដែលជាសក្តានុពលភាពយ៉ាងសំខាន់ ជាជំរកសត្វគ្រប់ប្រភេទ និង ជារបាំងការពារគ្រោះមហន្តរាយផ្សេងៗ ហើយក៏ជា ប្រភពចំណូលមួយយ៉ាងសំខាន់ សំរាប់ប្រជាជនឃុំអង្កោល។ តែបច្ចុប្បន្ន ការប្រើប្រាស់ធនធានធម្មជាតិ មានការប៉ះពាល់ខ្លាំង គឺធ្វើអោយធនធាន មានការថយចុះ ទទួលរងការរិចរិលជាបន្តបន្ទាប់ ពីសំណាក់ប្រជាជនមួយចំនួនក្នុងភូមិអង្កោល និង ទួលស្រងាំ ដោយសារការ រុករានកាប់រាំត យកដីសំរាប់លក់ ដុតព្រៃដើម្បីយកដីធ្វើកសិកម្ម មានការប្រើឧបករណ៍នេសាទ ល្មើសច្បាប់ផ្សេងៗ ក៏ដូចជាកំណើនប្រជាជន នាំអោយធនធានធម្មជាតិ ក្នុងឃុំអង្កោល មានការថយចុះនិង ហិនហោច ជាលំដាប់ ដូចនេះដើម្បីទប់ស្កាត់ និង ការពារ ធនធានធម្មជាតិ អោយមានចិរភាព ទើបឃុំអង្កោល សហការជាមួយ មន្ត្រីជំនាញរបស់ស្ថាប័នមន្ទីរពាក់ពន្ធ័ បង្កើតបានជាសហគមន៍ ចំនួន ពីរ ដូចខាងក្រោមៈ

| ល.រ | ដីសហគមន៍នៅក្នុងឃុំពងទឹក | | ដីសហគមន៍នៅក្នុងឃុំអង្កោល |
|---|---|---|---|
| | ប្រភេទសហគមន៍ | តាមចំណាត់ថ្នាក់ដីរដ្ឋ និងដីឯកជន | |
| ១ | សហគមន៍ការពារព្រៃកោងកាងឃុំអង្កោល | ដីសាធារណៈ/ឯកជនរបស់រដ្ឋ | ១០ |
| ២ | សហគមន៍នេសាទអង្កោល | ដីសាធារណៈ/ឯកជនរបស់រដ្ឋ | ១០ |
| ប្រភព: ទិន្នន័យប្រមូលពី ឃុំអង្កោល | | | |



**ឆ្នេរកំសាន្តនៅឃុំអង្កោល**

## ជំពូក២ ការវិភាគពីតម្រូវការសំរាប់អនាគត ឧបសគ្គ និង សក្តានុពល

### ២.១ តំបន់សើប

តំបន់ព្រៃកោងកាង ជាតំបន់មានជីវៈចំរុះ យ៉ាងពិសេស និងជាដែនជំរកត្រីពងកូន និង ឆ្នេរប្រវែង ១៣ គីឡូម៉ែត្រ ដែលមាន បរិស្ថានជុំវិញពណ៌បៃតង ដែលជាអំណោយផល របស់ ឃុំអង្កោល ។ ឃុំអង្កោល ក៏មានដីរមណីដ្ឋានធម្មជាតិ ១កន្លែងទៀត ដែលទាក់ទាញភ្ញៀវជាតិ និង អន្តរជាតិ គឺ រមណីដ្ឋានឆ្នេរអង្កោល។ បច្ចុប្បន្ននេះតំបន់ព្រៃកោងកាង នៅភូមិអង្កោល និង ភូមិទួលសាងាំ កំពុងរងការគំរាមកំហែងវាតដីព្រៃធ្វើលំនៅដ្ឋាន និង កាន់កាប់ជាកម្មសិទ្ធក្នុងគោលបំណងផ្សេងៗ។ ដូចនេះជាហេតុនាំអោយ ធនធានធម្មជាតិទទួលរងការបំផ្លិចបំផ្លាញ វិចរិលថយចុះជាលំដាប់ ។

តំបន់ទាំងនេះត្រូវតែរក្សាទុកដើម្បីជាលំនឹងបរិស្ថាន ជួយទប់ស្កាត់គ្រោះមហន្តរាយធម្មជាតិជាយថាហេតុ



**ព្រៃកោងកាងនៅឃុំអង្កោល**



**ឆ្នេរកំសាន្តនៅឃុំអង្កោល**

**អនុសាសន៍:**

ក្នុងនាមយើងខ្ញុំ ជាមេឃុំអង្គោល ក៏ដូចប្រជាជនទូទាំងឃុំ មានសេចក្តីសោមនស្ស និង សំដែងការដឹងគុណយ៉ាងខ្លាំង ចំពោះអង្គការ DANIDA / DFID ដែលបានផ្តល់នូវជំនួយ ដ៏វិសេសវិសាល ដល់ការការពារ និង ថែរក្សាធនធានធម្មជាតិនៅក្នុងឃុំយើងខ្ញុំ។ ព្រោះថានៅក្នុងឃុំយើងខ្ញុំសំបូរ ទៅដោយធនធានធម្មជាតិ ជាពិសេសព្រៃភ្នំ និងព្រៃដុះតាមមាត់សមុទ្រ ដែលព្រៃទាំងនេះ បានបង្កើត នូវចំណីជាច្រើន សំរាប់ទ្រទ្រង់ជីវភាពរបស់ប្រជាជន។ និងសូមអរគុណ ផងដែរនូវការផ្សព្វផ្សាយ ផ្តល់នូវចំណេះដឹងក្នុងការចេះ ប្រើប្រាស់ធនធានធម្មជាតិ ទាំងនេះឱ្យបានយូរអង្វែង និង មាននិរន្តភាព។

## ២.៤ គម្រោងការសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១ អត្រាកំណើន

នៅក្នុងអត្រា នៃការប្រែប្រួលចំនួនគ្រួសាររបស់ប្រជាពលរដ្ឋ នៅក្នុងអំឡុងឆ្នាំ ២០០៥ ដល់ ឆ្នាំ ២០០៦ ឃើញ ថាមានការថយចុះ ៣ ភាគរយ តាមពតិមាន បានអោយដឹងថាអាស្រ័យដោយ ប្រជាជនបានធ្វើចំណាក ស្រុកទៅ ប្រកប មុរបរធ្វើចំការ ធ្វើកម្មករនៅទីកន្លែងផ្សេងៗ ។ តែនៅឆ្នាំ ២០០៦ ទៅ ឆ្នាំ ២០០៧ អត្រានៃការប្រែប្រួល គឺមានការកើនឡើងវិញ ៣ ភាគរយនៃអត្រាកំណើនគ្រួសារ ទោះបីនៅ ឆ្នាំ ២០០៨ មានអត្រាកំណើនកើនឡើងខ្ពស់ ក៏ដោយ ក៏ អត្រាជាមធ្យម កំណើនគ្រួសារ កើនតែ ១ភាគរយ ស្មើ និង ១៥គ្រួសារ ។ ចំណែកអត្រាកំណើនប្រជាជន គ្មានការកើនឡើងទេ ។

| ចំនួនគ្រួសារ/ប្រជាជន | ចំនួនគ្រួសារ/ប្រជាជនតាមឆ្នាំ | | | | កំណើនប្រជាសាស្ត្រ | |
|---|---|---|---|---|---|---|
| | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | កំណើនមធ្យម | កំណើន/ឆ្នាំ |
| ចំនួនគ្រួសារសរុប | **១៤១៩** | **១៣៧១** | **១៤១៥** | **១៤៧៥** | | - |
| អត្រាកំណើនគ្រួសារ | | -៣% | ៣% | ៤% | ១% | ១៥គ្រួសារ |
| ចំនួនប្រជាជនសរុប | **៧៦១៨** | **៦៤៩៣** | **៦៦៦៩** | **៧៤២៣** | | - |
| អត្រាកំណើនប្រជាជន | | -១៥% | ៣% | ១១% | 0% | |

#### ២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ

តាមការធ្វើអត្រាកំណើនធម្មជាតិ នៃអត្រាកំណើនចំនួនគ្រួសារ និងអត្រាកំណើននៃចំនួនប្រជាជន នៅ ក្នុងឃុំ អង្កោល យើងពិនិត្យឃើញថាកំណើនមធ្យមជាសរុបគឺកើនឡើង **១%** ស្មើរនិង ១៥គ្រួសារ ឯអត្រាកំណើនប្រជាជនជាមធ្យមគ្មានការកើនឡើងទេ ។ ដូច្នេះដោយយោងតាមការធ្វើអត្រាកំណើនធម្មជាតិដែលយើងបានធ្វើនៅខាងលើនេះយើងអាចគណនារកចំណោលប្រជាសាស្ត្រ ទាំង ចំនួនគ្រួសារ និង ចំនួនប្រជាជនសរុប បាន តាមរូបមន្តដូចខាងក្រោម:

-ឆ្នាំ ២០១២ **មាន**ប្រជាជនសរុប ៨១៤៣ នាក់ ,ចំនួនគ្រួសារសរុប ១៥៤៩ គ្រួសារ

-ឆ្នាំ ២០១៧ **មាន**ប្រជាជនសរុប ៩៧៨០ នាក់ ,ចំនួនគ្រួសារសរុប ១៦២៣ គ្រួសារ

-ឆ្នាំ ២០២២ **មាន**ប្រជាជនសរុប ១២៩២៣ នាក់ ,ចំនួនគ្រួសារសរុប ១៦៩៦ គ្រួសារ

បើសិនជាពិនិត្យមើលទៅលើអត្រាកំណើននេះ

អត្រាកំណើនកុមារក៏មានការកើនឡើងដែរដែលអាចធ្វើអោយ មានការកើតឡើងនូវការខ្វះខាតអាគារសិក្សា ។ ហើយក្នុងនោះដែរ ចំពោះដីធ្លីនៅក្នុងឃុំ ក៏មានការខ្វះខាតដី ក្នុងការ ពង្រីកលើវិស័យកសិកម្មដែរ ដូច្នេះពីមួយឆ្នាំ ទៅមួយឆ្នាំ ប្រជាពលរដ្ឋមានការកើនឡើងជាលំដាប់ ជាកត្តាមួយធ្វើ អោយយើងត្រូវមាន ការកត់សំគាល់ទៅលើសក្តានុពល មួយចំនួន ដូចជាលទ្ធភាព នៃការពង្រីកផ្ទៃដីធ្វើអាគារសិក្សា ការពង្រីកផ្ទៃដីសំរាប់ធ្វើកសិកម្ម ឬ ការធ្វើស្រែបង្កើនរដូវ ការបង្កើននូវទិន្នផលកសិកម្ម ការបង្កើនមុខរបរសំរាប់ប្រជាជនចិញ្ចឹមជីវិត ការរៀបចំប្រពន្ធ័ស្រោចស្រព ការអភិរក្សនូវធនធានធម្មជាតិ និង កំណត់នៃការប្រើប្រាស់ ធនធានធម្មជាតិ ធនធានដី អោយបានសមស្រប ទើបអាចធានាបាននូវអត្រាកំណើននេះ ។

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អាយុក្រោម០៥ឆ្នាំ | ៧៧៤ | ៣៧៥ | ៨៥០ | ៤១១ | ៩៧៧ | ៤៧០ |
| អាយុ ០៥ឆ្នាំ | ៣២១ | ១៥៦ | ៣៣៤ | ១៦២ | ៣៥៥ | ១៧២ |
| អាយុពី ៦-១១ឆ្នាំ | ១២៧៤ | ៦១៧ | ១៤៧៦ | ៧១១ | ១៨២៨ | ៨៧៣ |
| អាយុពី ១២-១៤ឆ្នាំ | ៦៨២ | ៣៤០ | ៧៤២ | ៣៧០ | ៨៤០ | ៤១៨ |
| អាយុពី ១៥-១៧ឆ្នាំ | ៥១៨ | ២៤៧ | ៥៥៣ | ២៦២ | ៦០៩ | ២៨៧ |
| អាយុពី ១៨-២៤ឆ្នាំ | ៧៥២ | ៣៨៦ | ៨២៤ | ៤២៤ | ៩៤៤ | ៤៨៦ |
| អាយុពី ២៥-៦០ឆ្នាំ | ៣១២០ | ១៧០៥ | ៤២៣៣ | ២៣៥៥ | ៦៤៩៩ | ៣៧០២ |
| អាយុ ៦១ឆ្នាំឡើងទៅ | ៧០៤ | ៣២០ | ៧៦៧ | ៣៤៦ | ៨៧២ | ៣៨៨ |
| **ចំនួនប្រជាជនសរុប** | **៨១៤៣** | **៤១៤៥** | **៩៧៨០** | **៥០៤១** | **១២៩២៣** | **៦៧៩៧** |
| **ចំនួនប្រជាជនសរុប** | **៨១៤៣** | | **៩៧៨០** | | **១២៩២៣** | |
| **ចំនួនគ្រួសារសរុប** | **១៥៤៩** | | **១៦២៣** | | **១៦៩៦** | |

### ២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន

ចំនួនគ្រួសារ និងប្រជាពលរដ្ឋនៅក្នុង ឃុំ អង្កោល ក្នុងឆ្នាំ ២០០៨ មានចំនួន ១៤៧៥ គ្រួសារ ឯចំនួនប្រជា ពលរដ្ឋ មានចំនួន ៧៤២៣នាក់ ហើយមាន ១៤៤១ គ្រួសារ ស្មើរនិង ៩៧,៦៩ភាគរយ ដែលមាន មុខរបរធ្វើស្រែពឹងលើទឹកភ្លៀងជាចំបងដើម្បីចិញ្ចឹមជីវិត ។ ចំពោះដីលំនៅដ្ឋាននៅជនបទគឺ សំដៅទៅដល់ដីដែល ប្រើប្រាស់សំរាប់សង់ផ្ទះ និង សំរាប់ដាំដំណាំសួន គ្រួសារនៅជុំវិញ។ សំរាប់ឆ្នាំគោល ២០០៨ មានទំហំ ៤១៧ហិចតា សំរាប់ប្រជាជនប្រមាណជា១៤៤៧[១] គ្រួសារ ដូច្នេះទំហំដីសំរាប់មួយ គ្រួសារគិតជាមធ្យមគឺមាន ០,២៥ ហិកតា ដែលទំហំនេះអាច ជាទំហំសមស្របសំរាប់ការតាំងលំនៅដ្ឋាន ។ តម្រូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

| | | |
|---|---|---|
| - ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីលំនៅដ្ឋាន | ២៨ គ្រួ. x ០,២៥ | =៧ហត. |
| - កំណើនគ្រួសារ ២០២២ | ១៦៩៦ គ្រួ. x ០,២៥ | =៤២៤ហត. |
| | **សរុប** | **៤៣១ ហត** |

### ២.៤.៣ តម្រូវការដីកសិកម្ម

ដើម្បីធានាអោយបរិមាណផលស្រូវអាចផ្គត់ផ្គង់គ្រប់សំរាប់ប្រជាជនក្នុងឃុំអង្កោលទាំងមូលរយះពេលពេញ១ ឆ្នាំ ដូច្នេះតម្រូវអោយ ឃុំ ត្រូវពង្រីក បង្កើនផ្ទៃដីធ្វើស្រែដូចខាងក្រោមៈ

- ប្រជាជនដែលកើនថ្មីក្នុងឆ្នាំ ២០១២ ចំនួន ៨១៤៣នាក់ អាចទទួលបានបរិមាណស្រូវ ជាមធ្យម ប្រចាំឆ្នាំសំរាប់មនុស្សម្នាក់ពី ២៣៨ គ.ក្រ/នាក់ ដូច្នេះតម្រូវការស្រូវនៅឆ្នាំ២០១២ មានបរិមាណ ប្រហែល ៣០០៥.៣៦តោន ដើម្បីធានាសន្តិសុខស្បៀងក្នុងឃុំទាំងមូល ឃុំត្រូវបង្កើនផ្ទៃដីបង្កបង្កើតផលស្រែវស្សា អោយបានចំនួន ១៥០៣ហិចតា។
- ប្រជាជនដែលកើនថ្មីក្នុងឆ្នាំ ២០១៧ ចំនួន ៩៧៨០ នាក់ អាចទទួលបានបរិមាណស្រូវ ជាមធ្យមប្រចាំឆ្នាំ សំរាប់មនុស្សម្នាក់ ២៣៨ គ.ក្រ/នាក់ ដូច្នេះតម្រូវការស្រូវនៅឆ្នាំ ២០១៧ មានបរិមាណប្រហែល ៣៣៩៤.៩៧តោន។ ដើម្បីធានាសន្តិសុខស្បៀងក្នុងឃុំទាំងមូលត្រូវបង្កើនផ្ទៃដីបង្ក បង្កើនផល ស្រែវស្សាឱ្យបានចំនួន១៦៩៧ ហិចតា។

---

[១] ចំនួនគ្រួសារសរុប ១៤៧៥ គ្រួសារ ដកនឹងចំនួនគ្រួសារដែលមិនមានដីលំនៅដ្ឋាន ២៨ គ្រួសារ

- ប្រជាជនដែលកើនថ្មីក្នុងឆ្នាំ ២០២២ ចំនួន ១២៩២៣ នាក់ អាចទទួលបានបរិមាណស្រូវជាមធ្យមប្រចាំឆ្នាំ សំរាប់មនុស្ស ម្នាក់ ២៣៨ គ.ក្រ/នាក់ ដូច្នេះតម្រូវការស្រូវនៅឆ្នាំ ២០២២ មានបរិមាណប្រហែល ៤១៤៣ តោន ដើម្បីធានាសន្តិសុខស្បៀងក្នុងឃុំទាំងមូល ត្រូវបង្កើនផ្ទៃដីបង្កបង្កើតផល ស្រែវស្សាអោយបានចំនួន ២០៧២ ហិចតា។
- ប្រសិនបើឃុំអង្កោល ពុំមានលទ្ធភាពពង្រីកផ្ទៃដីបង្កបង្កើនផលបានទេឃុំអាចស្នើសុំជំនួយ បច្ចេកទេសកសិកម្ម ដើម្បីអោយទទួលបានទិន្នផលខ្ពស់ ឬ បង្កើនរដូវធ្វើស្រែវស្សាផង ធ្វើស្រែប្រាំង។

| ស្ថិតិ | ក្រឡាផ្ទៃ | ទិន្នផល | ឆ្នាំ ២០០៨ | | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|
| | | | នាក់ | ស្រូវសរុប | នាក់ | ស្រូវ សរុប | នាក់ | ស្រូវ សរុប | នាក់ | ស្រូវ សរុប |
| ស្រូវវស្សា | 1417 | 2 | 7423 | 2834 | 8143 | | 9780 | | 12923 | |
| | | | - | - | 720 | | - | - | - | - |
| បរិមាណស្រូវដែលទទួលបាន | - | - | - | - | - | 3005.36 | - | - | - | - |
| ពង្រីកផ្ទៃដីស្រែៈ ហិចតា | 1503 | | | - | - | 1503 | | | - | - |
| | | | | | | | 1637 | | | |
| បរិមាណស្រូវដែលទទួលបាន | | | | | | | | 3394.97 | | |
| ពង្រីកផ្ទៃដីស្រែៈ ហិចតា | 1697 | | | | | | | 1697.48 | | |
| | | | | | | | | | 3143 | |
| បរិមាណស្រូវដែលទទួលបាន | | | | | | | | | | 4143 |
| ពង្រីកផ្ទៃដីស្រែៈហិចតា | 2071.50 | | - | - | - | - | - | - | | 2072 |

### ២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

តម្រូវការដីសំរាប់ កិច្ចការ ពារបរិស្ថាន និង ធនធានធម្មជាតិ ឃុំអង្កោល នៅមានតំបន់ឆ្នេរនិងព្រៃកោងកាង ដូច្នេះដីដែលបានកំណត់នៅក្នុង តំបន់រសើប និង ដីផ្សេងៗទៀត ដែលមិនបានកំណត់ទៅក្នុងប្រភេទប្រើប្រាស់ដីផ្សេងៗទៀត គឺត្រូវតែទុកឱ្យនៅ ជាដីសំរាប់កិច្ចការពារបរិស្ថាន និង ធនធានធម្មជាតិ ពិសេសគឺព្រៃកោងកាងធម្មជាតិដែលជាប្រភពដ៏ ចំបងសំរាប់ ធនធានជលផល ។

### ២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធសង្គម

ជារួមហេដ្ឋារចនាសម័ន្ធសង្គមក្នុងរូបភាពតូចតាច គឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋាន ឬដីទីប្រជុំជន ដោយមិនបានពែ្ញកចេញដោយឡែកនោះទេ (ក្នុងនោះដីកប់ខ្មោច វត្ត អាស្រម ក៏គិតគូរក្នុងនេះដែរ) តែក្នុងនោះក៏មានការគិតគូរជារួម លើកលែងតែហេដ្ឋារចនាសម្ព័ន្ធ សង្គមដែលមានទ្រង់ទ្រាយធំ ទើបមានការគិតគូរដោយឡែក។ និយាយរួមដីសំរាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានកំណត់ជារួមជាមួយនឹងដីត្រៀមបំរុង សំរាប់ពង្រីកទីប្រជុំជន។

<u>តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ</u>

| សង្គម និសេវាកម្ម | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | ១ | ២ | ១ |
| សាលាបឋមសិក្សា | ១០ | ១២ | ២ |
| សាលាអនុវិទ្យាល័យ | ០ | ២ | ២ |
| សាលាវិទ្យាល័យ | ០ | ២ | ២ |
| មណ្ឌលសុខភាព | ១ | ២ | ១ |
| ប៉ុស្តិសុខភាព | ០ | ២ | ២ |
| ស្រះទឹកស្អាត | ៤១ | ៥៦ | ១៥ |
| អណ្តូងទឹកស្អាត | ៤៤ | ៦៤ | ២០ |
| កន្លែងចាក់សំរាម | ០ | ១ | ១ |
| ទីតាំងផ្សារ | ០ | ១ | ១ |
| ប៉ុស្តិនគរបាល | ១ | ០ | ០ |

### ២.៤.៥.១ តម្រូវការសាលារៀន

តារាងកំណើនកុមារ និងតម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១២-២០២២

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយ្យសិក្សា | ៣២១ | ០ | ០ | ៣៣៤ | ០ | ០ | ៣៥៥ | ០ | ១ |
| ថ្នាក់បឋមសិក្សា | ១២៧៤ | ០ | ១ | ១៤៧៤ | ០ | ៣ | ១៨២៨ | ១ | ៥ |
| ថ្នាក់អនុវិទ្យាល័យ | ៦៨២ | ២ | ៩ | ៧៤២ | ០ | ០ | ៨៤០ | ០ | ១ |
| ថ្នាក់វិទ្យាល័យ | ៥១៨ | ២ | ៦ | ៥៥៣ | ០ | ០ | ៦០៩ | ០ | ១ |
| ... | | | | | | | | | |

<u>សំគាល់</u>:

- តម្រូវការសាលារៀន និងបន្ទប់រៀនត្រូវបានគណនា ដោយផ្អែកលើចំនួនកុមារគ្រប់អាយុចូលរៀនតាមកំរិតសិក្សានីមួយៗ (តាមអត្រាចូលរៀន ១០០%)។
- ឆ្នាំ ២០១២ កុមារដែលគ្រប់អាយុត្រូវចូលរៀននៅថ្នាក់មត្តេយ្យសិក្សាចំនួន សរុប ៣២១នាក់ ដូចនេះចំនួនកុមារកើនឡើងតិចតួច ដូច្នេះមិនមានតម្រូវការសង់សាលាបន្ថែមទេ។ កុមារដែលគ្រប់អាយុត្រូវចូលរៀននៅថ្នាក់បឋមសិក្សា ចំនួន សរុប ១២៧៤ នាក់ មានការកើនឡើង ៩៤ នាក់ ដូច្នេះតម្រូវការសង់សាលាបន្ថែមតែ ១បន្ទប់ទេ។ កុមារដែលគ្រប់អាយុត្រូវចូល រៀននៅថ្នាក់អនុវិទ្យាល័យ ចំនួន សរុប ៦៨២នាក់ ប៉ុន្តែ ឃុំអង្កោល មិនមាន ថ្នាក់អនុវិទ្យាល័យនៅឡើយទេ ដូច្នេះតម្រូវការសង់សាលាបន្ថែម ចំនួន ២ ខ្នង មាន ៩ បន្ទប់ ដើម្បីជួយសំរួលដល់សិស្សា នុសិស្សក្នុងការរៀនសូត្រ។
- កុមារដែលគ្រប់អាយុត្រូវចូល រៀននៅថ្នាក់វិទ្យាល័យ ចំនួន សរុប ៥១៨ នាក់ ប៉ុន្តែ ឃុំអង្កោល មិនមានថ្នាក់វិទ្យាល័យនៅឡើយទេ ដូច្នេះតម្រូវការសង់សាលាបន្ថែម ចំនួន ២ខ្នង មាន ៦បន្ទប់ ដើម្បីជួយសំរួលដល់សិស្សានុសិស្សក្នុងការរៀនសូត្រ។
- ឆ្នាំ ២០១៧ កុមារដែលគ្រប់អាយុត្រូវចូលរៀននៅថ្នាក់មតេយ្យសិក្សាចំនួន សរុប ៣៣៤ នាក់ ដូចនេះចំនួនកុមារកើន ចំនួន ២០ នាក់ ។ កុមារដែលគ្រប់អាយុត្រូវចូល រៀននៅថ្នាក់បឋមសិក្សា ចំនួន សរុប ១៤៧៤ នាក់ មានការកើនឡើង ២១៤នាក់ ដូច្នេះតម្រូវការ សង់សាលាបន្ថែម ៣បន្ទប់។ កុមារដែលគ្រប់អាយុត្រូវចូលរៀននៅថ្នាក់អនុវិទ្យាល័យ ចំនួន សរុប ៧៤២នាក់ មានការកើនឡើង ៦០នាក់ ។ កុមារដែលគ្រប់អាយុត្រូវចូលរៀន

នៅថ្នាក់វិទ្យាល័យ ចំនួន សរុប ៥៥៣ នាក់ មានការកើនឡើង ៣៥ នាក់ ។

- ឆ្នាំ ២០២២ កុមារដែលគ្រប់អាយុត្រូវចូលរៀននៅថ្នាក់មត្តេយ្យសិក្សាចំនួន សរុប ៣៥៥ នាក់ ដូចនេះ ចំនួនកុមារកើន ចំនួន ៤១ នាក់ ដូច្នេះ កុមារនិងត្រូវការ១បន្ទប់ដើម្បីរៀន។ កុមារដែលគ្រប់អាយុត្រូវចូលរៀននៅថ្នាក់បឋមសិក្សា ចំនួន សរុប ១៨២៨ នាក់ មានការកើនឡើង ៣៥៤ នាក់ ដូច្នេះតម្រូវការសង់សាលាបន្ថែម ១ខ្នង មាន៥បន្ទប់។ កុមារដែលគ្រប់អាយុត្រូវចូល រៀននៅថ្នាក់អនុវិទ្យាល័យ ចំនួន សរុប៨៤០ នាក់ មានការកើនឡើង ៩៨ នាក់ ដូច្នេះតម្រូវការ សង់សាលាបន្ថែមតែ ១បន្ទប់។ កុមារដែលគ្រប់អាយុត្រូវចូលរៀននៅថ្នាក់វិទ្យា ល័យ ចំនួន សរុប ៦០៩ នាក់ មានការកើនឡើង ៥៦នាក់ កុមារនឹងត្រូវការ ១បន្ទប់ ដើម្បីរៀន។
- ក្នុង ០១ថ្ងៃ ត្រូវរៀន ០២ ពេល, សិស្សក្នុង ០១ ថ្នាក់ មានចំនួនជាមធ្យម ៤០ នាក់ ហើយសាលាដូច្នេះ បើពិនិត្យទៅលើចំនួនសិស្សក្នុងថ្នាក់ឃើញថា មានអត្រាសមល្មមអាចផ្តល់ឱកាសអោយកុមារ និង យុវជនបានចូលរៀនគ្រប់ៗគ្នា ។

## ២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

### ក. សេវាកម្មសុខភាព

| ល.រ | មណ្ឌល/ប៉ុស្តិសុខភាព | សមត្ថភាពផ្គត់ផ្គង់សេវាកម្ម | | | | |
|---|---|---|---|---|---|---|
| | | ចំនួន | គ្រែ/បន្ទប់ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | មណ្ឌលសុខភាព | ០១ | ៦បន្ទប់, ៥គ្រែ | ០៨នាក់ ស្រី ០៣ | ០៤នាក់ | ០៥នាក់ |

### ខ. ការផ្គត់ផ្គង់ទឹកស្អាត

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | | សំគាល់ |
|---|---|---|---|---|---|---|
| | | សរុប | ប្រើបាន ពេញ១ឆ្នាំ | ប្រើមិន បាន១ឆ្នាំ | ខូចខាត | |
| ១ | អណ្តូងស្នប់ | ២១ | ១៤ | ៧ | | គ្មានទឹកនៅរដូវប្រាំង |
| ២ | អណ្តូងលូ | ២៣ | ៩ | ១៤ | | គ្មានទឹកនៅរដូវប្រាំង |
| ៣ | ស្រះ | ៤១ | ៩៣ | ៣២ | | គ្មានទឹកនៅរដូវប្រាំង |

ប្រភព: របាយការណ៍ ស្តីពីស្ថានភាពឃុំអង្កោល ឆ្នាំ ២០០៩

- ថ្វីបើចំនួនប្រភពទឹកស្អាតមានមួយចំនួនក៏ពិតមែន ប៉ុន្តែដោយសារពុំមានថវិកាសំរាប់ថែទាំ និងជួសជុល

ជាបណ្តើរៗ បានធ្វើអោយអណ្តូងមួយចំនួនខូច អណ្តូង និងស្រះមួយចំនួនទៀត ស្រះខួររីងរាក់ប្រើមិនកើតនៅរដូវប្រាំង ។ ហេតុដូច្នេះទាមទារអោយមានការជីក ស្តារ អណ្តូង ស្រះថ្មីបន្ថែមមួយចំនួនទៀត ដើម្បីធានាអោយបាននូវការផ្គត់ផ្គង់ទឹកស្អាត សំរាប់ប្រើប្រាស់ទៅតាមសេចក្តីត្រូវការរបស់ប្រជាជន ។

### ២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា

នៅក្នុងការអភិវឌ្ឍន ទៅលើផ្នែកវប្បធិមជាកត្តា មួយចូលរួមចំណែកជំរុញ អោយមានសន្ទុះដល់ការអប់រំផ្នែកព្រះពុទ្ធសាសនា ។ វាល់ទីតាំងនីមួយៗតាមបណ្តាភូមិ ត្រូវបានផ្តល់លទ្ធភាព និងជួយសំរួល ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ផ្តល់មាន ឱកាសចូលរួម ពង្រីកលើការ ផ្សព្វផ្សាយ តាមរយៈការអប់រំដល់ យុវជន ដែលជាសរសរទ្រូង នៃប្រទេសជាតិ អោយជៀសផុតពី អំពើខុសច្បាប់ទាំងឡាយ ដែលរដ្ឋាភិបាលបានកំណត់ ។ ជាអាទិភាពសំរាប់ឃុំអង្កោល បច្ចុប្បន្ន ក៏បានត្រៀមសំរាប់កន្លែង គោរព ប្រពៃណីសាសនា នាថ្ងៃអនាគត ផងដែរ ។

**<u>តារាងការអភិវឌ្ឍន៍ និងអភិរក្សផ្នែកវប្បធម៌ និងសាសនា</u>**

| វប្បធម៌ និងសាសនា | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| ប្រាសាទ | 0 | 0 | - |
| ទីកន្លែងសាការៈបូជា | 0 | 0 | - |
| វត្តអារាម | ២ | ២ | 0 |
| ផ្សេងៗ | | | |

### ២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ប្រវែងឆ្នាំនេះ (ម) | ប្រវែង១៥ឆ្នាំ (ម) | បំរែបំរួល |
|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ | 0 | ១៨000 | 0២ |
| ផ្លូវក្រាលគ្រួសក្រហម | ២៥២៩ | ២៦៥00 | ៤ |
| ផ្លូវក្រាលគ្រួសក្រហមអន្តរឃុំ | ៨000 | ១៩000 | 0៦ |
| ផ្លូវលំដីសរ | ៩000 | ១៨000 | ៤ |
| ផ្លូវរទេះ | ១៨000 | ២១000 | ៥ |

| | | | |
|---|---|---|---|
| ទំបន់/ប្រឡាយមេ | ១៧00 | ១៩000 | ៦ |
| ទំបន់/ប្រឡាយរង | ១១៤0 | ៨000 | ៦ |
| លូទោល (១៣កន្លែង) | ២៦ម | ៥0ម | ១២ |
| លូភ្លោះ (៥កន្លែង) | ៥0ម | ១00ម | ៥ |
| លូទ្រិប (លូជ្រុង) (១កន្លែង) | ៦ម | ១២ម | ២ |
| ស្ពានបេតុង (៦កន្លែង) | ៤២ម | ៦២ | ២ |
| សំណង់ផ្លូវបង្ហៀរទឹក (៧កន្លែង) | ២១ម | ៣0 | ៣ |
| ទ្វារទឹក | ១0ម | ២៥ម | ១៥ |
| ផ្សេងៗ | | | |

- **<u>ផ្លូវក្រាលកៅស៊ូ</u>**

  -ខ្សែទី១ ចាប់ផ្ដើមពីផ្លូវវាលវង្ស ដល់ លក មានប្រវែង ១៣៥00 ម

  - ខ្សែទី២ ចាប់ពីផ្ទល់វត្តព្រៃតាកុយ ដល់ មណ្ឌលសុខភាព មានប្រវែង ៤៥00ម

- **<u>ផ្លូវក្រាលគ្រួសក្រហម</u>**

  <u>ភូមិអំពែង</u>

  -ខ្សែទី១ ចាប់ពីផ្ទះតាសៀន ទៅ សាលារៀនព្រៃកតានេន មានប្រវែង ២២00 ម

  -ខ្សែទី២ ចាប់ពីផ្លូវបែកស្រែយស់ ទៅ សមុទ្រ មានប្រវែង  ៣៥00ម

  -ខ្សែទី៣ ចាប់ពីផ្ទះ យាម ទៀម ទៅ ផ្ទះ នាង ធិញ មានប្រវែង  ២៣00ម

  -ខ្សែទី៤ ចាប់ពី ផ្ទះ តាហេន ទៅ ស្ពានកំពង់រោង មានប្រវែង  ២000ម

  -ខ្សែទី៥ ចាប់ពី ផ្ទះ តា សៀន ទៅ ទំនប់ព្រៃកតានេន មានប្រវែង  ១២00ម

  <u>ភូមិអង្កោល</u>

  -ខ្សែទី៦ ចាប់ពី ខាងត្បូងប៉ុស្តិ៍ ទៅដល់ ទ្វារអ្នកតា  មានប្រវែង ២៤00ម

  -ខ្សែទី៧ ចាប់ពី ផ្ទះ ស្រេង ទិញ ទៅដល់ ស្រែយស់  មានប្រវែង ៣៥00ម

  -ខ្សែទី៨ ចាប់ពី ម៉ា រ៉ែត ទៅដល់ផ្ទះ កែវ យន   មានប្រវែង ២៥00ម

  <u>ភូមិទួលសាងាំ</u>

  -ខ្សែទី៩ ចាប់ពីវត្តទួលសាងាំ  ទៅដល់ កំពង់រោង   មានប្រវែង ១៥00ម

-ខ្សែទី១០ ចាប់ពីត្រពាំងសាងាំ ទៅដល់ផ្ទះប៉ាសុង មានប្រវែង ១៧០០ម

ភូមិកោះសោម

-ខ្សែទី១១ ចាប់ពីផ្ទះកួច តាវ ទៅដល់ផ្ទះ យាន អ៊ុក មានប្រវែង ១២០០ម

-ខ្សែទី១២ ចាប់ពីខាងត្បូងវត្តព្រៃតាកុយ ទៅដល់ផ្ទះគង់សាយ មានប្រវែង ២៥០០ម

- **ប្រឡាយមេ**

-ចាប់ពីកោះសោម ទៅតំបន់ស្រែយល់ មានប្រវែង ៤០០០ម

-ចាប់ពីកោះសោម មកផ្ទះ ម៉ៅ ឈុន មានប្រវែង ៤០០០ម

-ប្រឡាយ ចិនទ្រុង មានប្រវែង ២០០០ម

-ប្រឡាយ ធីង បឿង មានប្រវែង ២០០០ម

-ពីផ្ទះព្រំ ត្រឹក ដល់ អ៊ូរាំង មានប្រវែង ៣៥០០ម

-ខាងត្បូងផ្ទះតាសេង ដល់ ថ្នល់ដាច់ មានប្រវែង ៣៥០០ម

- **ប្រឡាយរង**

ភូមិកោះសោម

-ពីខាងត្បូងវត្តព្រៃតាកុយ ដល់ ផ្ទះ គង់ សាយ ២៥០០ម

-ពីផ្ទះ យាន អ៊ុក ដល់ ស្ពានត្រពាំងម្អម ២៥០០ម

ភូមិទួលសាងាំ

-ពីផ្ទះ កេង ទួន មក តួច សេង ២០០០ម

-ពីផ្ទះ កេង ទួន មកផ្ទះ លឿង យួន ១០០០ម

-ពីផ្ទះ កៅ រិន មកខាងជើងភូមិ ផ្ទះតួច សេង ១៥០០ម

-ពីផ្ទះ លី ខេង ដល់ ខាងត្បូងភូមិកាសេង ១៥០០ម

**ផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារផ្នែកចនាសម្ព័ន្ធសង្គម និង សេវាកម្ម**

| សង្គម និសេវាកម្ម | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | ១ | ១ | ១ |
| សាលាបឋមសិក្សា | ១០ | ១២ | ២ |
| សាលាអនុវិទ្យាល័យ | ០ | ២ | ១ |
| សាលាវិទ្យាល័យ | ០ | ២ | ១ |

| | | | |
|---|---|---|---|
| មណ្ឌលសុខភាព | ១ | ២ (កោះសោម) | ១ |
| ប៉ុស្តិ៍សុខភាព | 0 | ២កន្លែង -១ នៅអំពែង<br>-១ នៅអង្កោល | ២ |
| ស្រះទឹកស្អាត | ៤១ | ៥៦ | ១៥ |
| អណ្តូងទឹកស្អាត | ៤៤ | ៦៤ | ២0 |
| កន្លែងចាក់សំរាម | 0 | ១ (៥00ម²) | ១ |
| ទីតាំងផ្សារ | 0 | ១ (អង្កោលៈ ១ ហ.ត) | ១ |
| ប៉ុស្តិ៍នគរបាល | ១ (អង្កោល) | ២(អំពែង)ជិតមណ្ឌលសុខភាព | ១ |
| ផ្សេងៗ | | | |

# ជំពូក ៣ ផែនការប្រើប្រាស់ដីអនាគត

## ៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី

### ៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល

នៅក្នុង ឃុំអង្កោល មានឆ្នេរអង្កោលដែលជាសម្បត្តិធម្មជាតិដ៏មានតំលៃ សំរាប់ទាក់ទាញភ្ញៀវជាតិ និង អន្តរជាតិមកកំសាន្ត ។ ក្រៅពីនេះ ក៏មានធនធានធម្មជាតិដែលមានសារះប្រយោជន៏ មួយទៀតដែរគឺ ព្រៃកោងកាងដែលជាសក្តានុ-ពល យ៉ាងសំខាន់ដែល ជាជំរកសត្វគ្រប់ប្រភេទ និង ជារបាំងការពារគ្រោះមហន្តរាយផ្សេងៗ ហើយក៏ជា ប្រភពចំណូលមួយយ៉ាងសំខាន់ សំរាប់ប្រជាជនឃុំអង្កោល ។

### ៣.១.២ តម្រូវការដីតាមប្រភេទ

តារាងតម្រូវការនៃការប្រើប្រាស់ដីអនាគត

| ល.រ | ប្រភេទប្រើប្រាស់ដីអនាគត | ទំហំ ( គិតជាហិចតា) | ចំនួន ( កន្លែង) |
|---|---|---|---|
| ១ | ដីលំនៅដ្ឋាន ប្រជុំជន | ៣៨៦ | ១ |
| ២ | ដីលំនៅដ្ឋាន ភូមិ | ២០០ | ២ |
| ៣ | ដីស្រែប្រាំង និង ស្រែវស្សា | ៨៧៧.៥ | ១ |
| ៤ | តំបន់ទេសចរណ៍ធម្មជាតិ | ៤៧.៥ | ២ |
| ៥ | តំបន់ការពារព្រៃកោងកាងស្ពឹង | ៥១ | ៤ |

## ៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់

### ៣.២.១ បញ្ញត្តិលើការប្រើប្រាស់ដី និង អនុសាសន៍

- **ដីលំនៅដ្ឋានភូមិ និង ប្រជុំជន លេខកូដ F1100 និង F1200:**
  - -ត្រូវរក្សាទុក ២៥ម៉ែត្រ ពីអក្ស័រផ្លូវជាតិ និង ១៥ ម៉ែត្រ ពីផ្លូវផ្សេងៗ
  - -គោរពតាមជួរតំរង់
  - -គោរពតាមកំពស់អាគារដែលចេញដោយ មន្ទីររៀបចំដែនដី
  - -រក្សាទុកគន្លាតផ្លូវ និង ចំណីផ្លូវ
  - -រក្សាទុកចំណីប្រឡាយខាងមុខ

-គួររៀបចំសួនច្បារ និង ដើមឈើ មុខផ្ទះ

- គិតគូរពីផលប៉ះពាល់ធនធានធម្មជាតិ និង បរិស្ថាន

- **ដីស្រែប្រាំង លេខកូដ F2150-01:**

  -ត្រូវមានប្រពន្ធ័ទឹកចេញ ចូល គ្រប់គ្រាន់

  - ហាមដាច់ខាតមិនឱ្យប្រើថ្នាំពុលគីមីផ្សេងៗ

  - មិនត្រូវជីកស្រះ ឬលើកជាទំនប់ស្ទាក់ទឹកជាទ្រង់ទ្រាយធំ

  -គិតគូរពីផលប៉ះពាល់ធនធានធម្មជាតិ និង បរិស្ថាន

- **តំបន់ទេសចរណ៍ធម្មជាតិ លេខកូដ F6500-01 :**

  -ហាមមិនអោយសង់សំណង់អាគារខ្ពស់ៗ

  -ហាមមិនអោយគាស់ ឬ ដាប់រំលើងថ្មភ្នំ

  -ហាមវាតដីព្រៃភ្នំក្នុងគោលបំណងណាមួយ

  -គិតគូរពីផលប៉ះពាល់ធនធានធម្មជាតិ និង បរិស្ថាន

- **តំបន់ការពារព្រៃកោងកាងស្តើង លេខកូដ F3610-01:**

  -ហាមកាប់ ឬ រំលោភយកព្រៃកោងការធ្វើជាកម្មសិទ្ធ

  -ហាមមិនអោយប្រើប្រាស់ថ្នាំពុលគីមីផ្សេងៗក្នុងនាទីព្រៃកោងកាង

  -ហាមឃាត់រាល់ឧបករណ៍ល្មើសច្បាប់ផ្សេងៗ

  -គួរជួយគ្នាថែរក្សា និង ដាំដុះឡើងវិញ

## ៣.២.២ ផែនទីប្រើប្រាស់ដីអនាគត

ដើម្បីធានាបានការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តភាពឃុំអង្កោល បានរៀបចំផែនការសំរាប់ធ្វើការ អភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួនរយៈពេល១៥ឆ្នាំ ដូចតទៅ:

**ផ្នែកហេដ្ឋារចនាសម្ព័រូបវន្តៈ** ឃុំអង្កោល មានគំរោងចាក់ថ្មល់កៅស៊ូចំនួន ២ ខ្សែ ,ចាក់គ្រួសក្រហមលើផ្លូវលំដីសដែលមានស្រាប់ចំនួន ១២ ខ្សែ លើកផ្លូវលំ ៤ខ្សែ ស្ពានប្រឡាយមេចំនួន ៦ខ្សែ ប្រឡាយរង ៦ខ្សែ ធ្វើទ្វារទាក់ទឹកចំនួន ១៦កន្លែង បន្ថែមទៀតដាក់លូចំនួន ១៩កន្លែង និង ធ្វើស្ពានបេតុងចំនួន ៦ កន្លែងទៀត។

**ផែនការប្រើប្រាស់ដីទៅអនាគតៈ** ឃុំអង្កោល បានគ្រោងរៀបចំទីតាំងលំនៅដ្ឋានថ្មី នៅតាមបណ្តោយសងខាង

ផ្លូវចាប់ពីព្រំប្រទល់ពងទឹក រហូតដល់ភូមិទួលស្រងាំ ចំនួន ១៧៥ហិចតា និង ១កន្លែងទៀតនៅភូមិ អង្កោល ចំនួន ២៥ ហិចតា និង អភិវឌ្ឍនទីប្រជុំជន នៅតំបន់ភ្នំពោន ប្រហែល ៣៨៦ហិចតា ។សំរាប់ដីកសិកម្ម ឃុំមានគម្រោង ពង្រីកការធ្វើស្រែអោយបានពីរដូវ នៅតំបន់កោះសោម និង ទួលស្រងាំ ប្រមាណប្រហែល ៨៧៧,៥ ហ.ត ។ ក្នុងផែនការឃុំ អង្កោល ក៏មាន គម្រោង រៀបទុកជាតំបន់ទេសចរណ៏ធម្មជាតិ ចំនួន២កន្លែងផងដែរ មានដូចជា: តំបន់ឆ្នេរ និង រមណីយដ្ឋានភ្នំ អង្កោល ចំនួន៤៧,៥ហិចតា ហើយក៏បានបង្កើតជាសហគមន៏ការពារ ព្រៃឈើផង និង សហគមន៏នេសាទផងដែល ។

### ៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី

ក្នុងទិសដៅនេះដើម្បីឆ្លើយតប ទៅនិងកំណើនប្រជាពលរដ្ឋក្នុងឃុំសំរាប់ឆ្នាំ ២០២២ ដែលតំរូវអោយមានការបែងចែកក្បាលដី ។ ដូច្នេះឃុំអង្កោល គួរតែប្រើប្រាស់ដីសំរាប់អភិវឌ្ឍន៏ជូនដល់ប្រជាពលរដ្ឋដោយ រៀបចំអោយមាន សោភណ័ភាពជាទី ប្រជុំជន មានផ្សារលក់ដូរ សង់ផ្ទះល្វែង និង សេវាកម្មផ្សេងៗ ហើយធានាបាននៅសន្តិសុខស្បៀង សំរាប់តំរូវការដល់ជីវភាព រស់នៅរបស់ប្រជាពលរដ្ឋ ទូទាំងឃុំ ។

ដើម្បីនានាបាននៅការប្រើប្រាស់ដីប្រកបដោយចិរភាព និង សមធម៏ ជូនប្រជាពលរដ្ឋ ក្នុងឃុំអង្កោល ទាំងមូល ឃុំ បានអភិវឌ្ឍន ផែនការប្រើប្រាស់ដីរបស់ខ្លួន យោងសំខាន់ទៅតាម ផែនការមេរយះ១៥ឆ្នាំរបស់ ខេត្តកែប និង ស្ថានភាពជាក់ស្តែងដី ព្រមទាំង តម្រូវការរបស់ប្រជាជន ។ ដូនេះដើម្បីអនុលោមតាមយុទ្ធសាស្រ្ត អភិវឌ្ឍនរបស់ខេត្ត ការប្រើប្រាស់ដីនៅក្នុង ឃុំអង្កោល ត្រូវបានបែងចែកទៅតាមគោលការណ៏ ដើម្បី អភិវឌ្ឍនមួយចំនួន ដូចខាងក្រោម :

#### ៣.២.៣.១ ដីលំនៅដ្ឋាន ប្រជុំជន

**-ដីលំនៅដ្ឋាន ប្រជុំជន លេខកូដ F1100-01:**

ការកំនត់ការអភិវឌ្ឍននេះយោងតាមផែនការមេរបស់ខេត្ត ដោយកំនត់ដីតំបន់នោះជាកន្លែងដីតំបន់សណ្ឋាគារ និង ដីបំរុងអភិវឌ្ឍន ដូច្នេះតាមផែនការប្រើប្រាស់ដី ឃុំសម្រេចប្រែក្លាយដីចំនួន ៣៨៦ហិចតា តំបន់នោះអោយ ទៅជាដីលំនៅដ្ឋាន ប្រជុំជន ។ ដែលពីមុនជា ប្រភេទដីដូចជា :

-ដីស្រែលាយភូមិ : ចំនួន ៣៦៨ ហ.ត

#### ៣.២.៣.២ ដីស្រែប្រាំង និង ស្រែវស្សា

**-ដីស្រែប្រាំង និង ស្រែវស្សា លេខកូដ F2150-01:**

ឆ្លងតាមការប្រជុំពិភាក្សាគ្នាជាច្រើនលើកមក ឃុំបានត្រៀមរៀបចំដីចំនួន ៨៧៧,៥ហិចតា សំរាប់ធ្វើស្រែបានពីរដូវ ។ ដែលពីមុនជា ប្រភេទដីដូចជា :

-ដីស្រែលាយភូមិ  : ចំនួន ៨៧៧,៥ ហ.ត

### ៣.២.៣.៣  តំបន់ទេសចរណ៍ធម្មជាតិ

**-តំបន់ទេសចរណ៍ធម្មជាតិ លេខកូដ F6500-01:**

រមណីយដ្ឋានភ្នំ អង្កោល ចំនួន៤៧,៥ហិចតា  ជារមណីដ្ឋានទេសចរណ៍ធម្មជាតិ និង ជាកន្លែងការពារ អភិរក្ស ដោយ សហគមន៍ ការពារព្រៃឈើផងដែរ ។ ដែលពីមុនតំបន់នេះជា :

-តំបន់ព្រៃគម្ពោត ចំនួន ៤៧,៥ ហិចតា

### ៣.២.៣.៤  តំបន់ការពារព្រៃកោងកាងស្តើង

**-តំបន់ការពារព្រៃកោងកាងស្តើង លេខកូដ F3610-01:**

ឃុំអង្កោល  មានតំបន់ការពារព្រៃកោងកាងស្តើង  ចំនួន  ៥១  ហិចតា  ដែលមានទីតាំងនៅភូមិអង្កោល  និង ទួលស្រងាំ ។

## ឧបសម្ព័ន្ធ

## ២.១ការប្រឈម/ឧបសគ្គ

| ១.១. បញ្ហាប្រឈម និងសក្ដានុពល (ផ្អែកលើការវិភាគ បញ្ហា/មូលហេតុ/ដំណោះស្រាយ) ឃុំអង្កោល | | | |
|---|---|---|---|
| **បញ្ហា** | **ទីតាំងនៃបញ្ហា** | **មូលហេតុ** | **ដំណោះស្រាយ** |
| ១ | **២** | **៣** | **៤** |
| **១.ទិន្នផលស្រូវ ដំណាំ ទាប** | - ភូមិទួលស្រងាំ<br>- ភូមិកោះសោម<br>- ភូមិអំពែង<br>- ភូមិអង្កោល | -ប្រើជីគីមីច្រើន<br>-.ខ្វះបច្ចេកទេស<br>-ដីខូចគុណភាព | -ធ្វើស្រែបង្ហាញ (គំរូ)<br>-បណ្ដុះបណ្ដាលពីវិធីជ្រើសរើសពូជ<br>-បណ្ដុះបណ្ដាលបច្ចេកទេសធ្វើជីកំប៉ុស្តិ<br>-ផ្សព្វផ្សាយបច្ចេកទេសកសិកម្ម |
| **២.ខ្វះទឹកស្រោច ស្រព** | - ភូមិទួលសាងាំ<br>- ភូមិកោះសោម<br>- ភូមិអំពែង<br>- ភូមិអង្កោល | -ការចែកចាយទឹកពុំមានភាពត្រឹមត្រូវ | -បង្កើតគណះកម្មការប្រើប្រាស់ទឹក<br>-ស្ដារស្រះទឹករួម |
| **៣.សត្វមានជំងឺ** | - ភូមិទួលស្រងាំ<br>- ភូមិកោះសោម | -ខ្វះ បច្ចេកទេសចិញ្ចឹម សត្វ<br>-ខ្វះពូជជ្រូក និង មាន់ | -ផ្ដល់ពូជសត្វមានគុណភាពខ្ពស់<br>-ផ្ដល់បច្ចេកទេសចិញ្ចឹមសត្វ |

| | | | |
|---|---|---|---|
| | - ភូមិអំពែង<br>- ភូមិអង្កោល | ដែលមានគុណភាពល្អ | -ផ្តល់វ៉ាក់សាំងការពារជំងឺសត្វ |
| **៤.ខ្វះទីផ្សារសម ស្របសំរាប់លក់ ផលិតផល** | - ភូមិទួលស្រងាំ<br>- ភូមិកោះសោម<br>- ភូមិអំពែង<br>- ភូមិអង្កោល | -ខ្វះការយល់ដឹងពីទីផ្សារ<br>-គ្មានក្រុម ឬ បណ្តាញទីផ្សារ | -បណ្តុះបណ្តាលពត៌មានទីផ្សារ<br>-ស្វែងរកទីផ្សារតាមរយះចងក្រុង ជាក្រុម |
| **៥.ផ្លូវខូច** | -ភូមិកោះសោម | -ប្រើប្រាស់រាល់ថ្ងៃ | -ជួសជុល និង ចាក់គ្រួសក្រហម |
| **៦.ធានធានមនុស្សមានកំរិត** | - ភូមិទួលស្រងាំ<br>- ភូមិកោះសោម<br>- ភូមិអំពែង<br>- ភូមិអង្កោល | -ខ្វះសាលារៀន<br>-ជីវភាពខ្វះខាត<br>-ឪពុក ម្តាយ ខ្វះការយល់ដឹង (អក្ខរជន) | -ផ្តល់អាហាររូបករណ៏ដល់សិស្សក្រីក្រ<br>-បង្កើតអនុវិទ្យាល័យក្នុងឃុំ<br>-ផ្សព្វផ្សាយការអប់រំដល់អាណា ព្យាបាល<br>-បំផុសអោយចូលរៀនអក្ខរកម្ម |
| **៧.ផលនេសាទថយចុះ** | - ភូមិទួលស្រងាំ<br>- ភូមិកោះសោម<br>- ភូមិអំពែង<br>- ភូមិអង្កោល | -ប្រើប្រាស់ឧបករណ៏ ទំនើបខុសច្បាប់<br>-ការអនុវត្តច្បាប់ធូររលុង | -លប់បំបាត់ឧបករណ៏នេសាទខុសច្បាប់<br>-ពង្រឹងសហគមន៏នេសាទ<br>-ផ្សព្វផ្សាយច្បាប់ជលផល |

| | | | |
|---|---|---|---|
| | | | |
| **៨.ទំនាស់ដីធ្លី** | - ភូមិទួលស្រងាំ<br>- ភូមិកោះសោម<br>- ភូមិអំពែង<br>- ភូមិអង្កោល | -ខ្វះការយល់ដឹងពីច្បាប់ភូមិបាល<br>-ខ្វះឯកសារបញ្ជាក់ | - ផ្សព្វផ្សាយច្បាប់ ភូមិបាល<br>- ផ្សព្វផ្សាយច្បាប់គណៈកម្មការសុយោដី<br>-ផ្តល់បណ្ណ័កម្មសិទ្ធ |
| **៩.ប្រើអំពីហឹង្សា** | - ភូមិទួលស្រងាំ<br>- ភូមិកោះសោម<br>- ភូមិអំពែង<br>- ភូមិអង្កោល | -លេងល្បែងស៊ីសង<br>-ខ្វះមុខរបប<br>-ខ្វះការយល់ដឹង | -លប់បំបាត់ល្បែងស៊ីសងគ្រប់ប្រភេទ<br>- ផ្សព្វផ្សាយច្បាប់ស្តីពីអំពើហឹង្សាក្នុងគ្រួសារ<br>-ផ្តល់មុខរបប |
| **១០.ខ្វះការយល់ដឹងពីសេវាកម្មមណ្ឌលសុខភាព** | - ភូមិទួលស្រងាំ<br>- ភូមិកោះសោម<br>- ភូមិអំពែង<br>- ភូមិអង្កោល | -ខ្វះការយល់ដឹងពី អនាម័យសុភាព<br>-ខ្វះប្រពន្ឋ័ផ្សព្វផ្សាយទូលំទូលាយ | -ផ្សព្វផ្សាយពីសេវាកម្មផ្សេងៗរបស់មណ្ឌលសុខភាព( ចាក់វ៉ាក់សាំង ពិនិត្យផ្ទៃពោះ ពន្យាកំនើត ។ល ។)<br>-ផ្តល់ការព្យាបាលមិនគិតប្រាក់ដល់ប្រជាជនក្រីក្រ |

## ២.២ កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ

| សេចក្តីត្រូវការអភិវឌ្ឍន៍ | គោលដៅអភិវឌ្ឍន៍ | យុទ្ធសាស្ត្រអភិវឌ្ឍន៍ | សកម្មភាពជាអទិភាព |
|---|---|---|---|
| -ព្រៃកោងកាងកើនឡើង | -ឆ្នាំ ២០១២ ព្រៃកោងកាងកើនឡើង ៤0% ទៅ ៨0% | -ពង្រឹងការពារថែរក្សា និង ប្រើប្រាស់ ប្រកបដោយនិរន្តរភាព | -បង្កើនសហគមន៍ការពារព្រៃកោងកាង<br>-<br>ផ្តល់ចង្រ្កានប្រើឧស្ម័នដែលផលិតពីលាមកសត្វ<br>-ផ្សព្វផ្សាយច្បាប់ |
| -ធនធានជលផលកើនឡើងវិញ | -ឆ្នាំ ២០១២ ធនធានជលផលកើនឡើងវិញ | -កែលំអប្រព័ន្ធគ្រប់គ្រង និង ការអភិរក្សធនធានជលផល | -បង្កើនសហគមន៍នេសាទ<br>-ពង្រឹងការអនុវត្តច្បាប់ |
| -<br>មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ | -ឆ្នាំ ២០១២ ទូទាំងសង្កាត់មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ | -កែលំអប្រព័ន្ធស្រពស្រប | -ជួសជុលទំនប់ទឹកស្ពានប្រឡាយ<br>-សំណង់ទ្វារស្ទាក់ទឹក<br>-លូបង្ហូរទឹក |

| | | | |
|---|---|---|---|
| -បច្ចេកទេសដាំដុះនិង កែប្រែគុណភាពដី | -បង្កើនទិន្នផលពី១,៥តោនដល់៣តោន/ហ.ត | - បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម | -បណ្តុះបណ្តាលបច្ចេកទេសដាំដុះ<br>-បណ្តុះបណ្តាលបច្ចេកទេសប្រើជីគីមី និង ថ្នាំពុល<br>-ផ្តល់ពូជស្រូវ និង ដំណាំមានទិន្នផលខ្ពស់<br>-បណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ |
| -កុមារបានចូលរៀនអស់ | - អោយកុមារបានចូលរៀនបានពី៣៦%ដល់៩៨% យ៉ាងតិច | -កែលំអប្រព័ន្ធអប់រំពីកំរិតបឋមសិក្សាដល់បធ្យមសិក្សា | -សាងសង់អគារសិក្សាបន្ថែម<br>-បង្កើតថ្នាក់មតេយ្យសិក្សា<br>-ផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រ<br>-លុបបំបាត់ការប្រើប្រាស់ពលកម្មលើកុមារ<br>-អប់រំនិងជំរុញកុមារអោយបានចូលរៀន |

**កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ**

| **សេចក្តីត្រូវការអភិវឌ្ឍន៍** | **គោលដៅអភិវឌ្ឍន៍** | **យុទ្ធសាស្ត្រអភិវឌ្ឍន៍** | **សកម្មភាពជាអទិភាព** |
|---|---|---|---|
| -ព្រៃកោងកាងកើនឡើង | -ឆ្នាំ ២០១២ ព្រៃកោងកាងកើនឡើង ៤០%ទៅ ៨០% | -ពង្រឹងការពារថែរក្សា និង ប្រើប្រាស់ប្រកបដោយនិរន្តរភាព | -បង្កើនសហគមន៍ការពារព្រៃកោងកាង<br>-ផ្តល់ចង្រ្កានប្រើឧស្ម័នដែលផលិតពីលាមកសត្វ<br>-ផ្សព្វផ្សាយច្បាប់ |
| -ធនធានជលផលកើនឡើងវិញ | -ឆ្នាំ ២០១២<br>ធនធានជលផលកើនឡើងវិញ | -កែលំអប្រព័ន្ធគ្រប់គ្រង និង ការអភិរក្សធនធានជលផល | -បង្កើនសហគមន៍នេសាទ<br>-ពង្រឹងការអនុវត្តច្បាប់ |
| -មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ | -ឆ្នាំ ២០១២<br>ទូទាំងសង្កាត់មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ | -កែលំអប្រព័ន្ធស្រពស្រប | -ជួសជុលទំនប់ទឹកស្តារប្រឡាយ<br>-សំណង់ទ្វារស្ទាក់ទឹក<br>-លូបង្ហូរទឹក |
| -បច្ចេកទេសដាំដុះនិងកែប្រែគុណភាពដី | -<br>បង្កើនទិន្នផលពី១,៥តោនដល់៣តោន/ហ.ត | -បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម | -បណ្តុះបណ្តាលបច្ចេកទេសដាំដុះ<br>-បណ្តុះបណ្តាលបច្ចេកទេសប្រើជីគីមី និង ថ្នាំពុល<br>-ផ្តល់ពូជស្រូវ និង ដំណាំមានទិន្នផលខ្ពស់<br>-បណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្តិ៍ |
| -កុមារបានចូលរៀនអស់ | - | -កែលំអប្រព័ន្ធអប់រំពីកំរិតបឋម | -សាងសង់អគារសិក្សាបន្ថែម |

| | | | |
|---|---|---|---|
| | អោយកុមារបានចូលរៀនបានពី៣៦%ដល់៩៨%<br>យ៉ាងតិច | សិក្សាដល់បធ្យមសិក្សា | -បង្កើតថ្នាក់មតេយ្យសិក្សា<br>-ផ្តល់អាហាររូបករណ៍ដល់សិស្សក្រីក្រ<br>-លុបបំបាត់ការប្រើប្រាស់ពលកម្មលើកុមារ<br>-អប់រំនិងជំរុញកុមារអោយបានចូលរៀន |

**ឧបសម្ពន្ធ័**

**បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ ក្នុងរយៈពេល ១៥ឆ្នាំ**

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១ [១] | ៥ឆ្នាំទី២ [២] | ៥ឆ្នាំទី៣ [៣] | |
| ២.៦.១. | គំរោងផ្នែកហេដ្ឋរចនាសម្ព័ន្ធ | | | | | | |
| | **២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** | | | | | | |
| | **១.១. ផ្លូវថ្នល់** | | | | | | |
| | ១.១.១. ផ្លូវក្រាលកៅស៊ូ ( ២ ខ្សែ ) | ១៨ | គម | ១ | ១ | | |
| | ១.១.២. ផ្លូវក្រាលគ្រួសក្រហមនិងជួសជុល ( ១២ ខ្សែ ) | ២៦ | គម | ៤ | ៤ | ៤ | |
| | ១.១.៣. ប្រវែងផ្លូវក្រាលដីស ( ៤ ខ្សែ ) | ៦,៣ | គម | ២ | | ២ | |
| | ១.១.៤. ផ្លូវរទេះ/ថ្មើជើង | | | | | | |
| | **១.២. ប្រព័ន្ធស្រោចស្រព** | | | | | | |
| | ១.២.១. ប្រឡាយមេ ( ៦ខ្សែ) | ១៩ | គម | ២ | ២ | ២ | |
| | ១.២.២. ប្រឡាយរង( ៦ខ្សែ) | ៨ | គម | ២ | ២ | ២ | |

[១] - ៥ឆ្នាំទី១ ( ២០០៨-២០១២ ) : បញ្ចូលគំរោងទាំងអស់របស់ **CDP** ឆ្នាំ ២០០៨-២០១២ រួមទាំងគំរោងផ្នែកប្រើប្រាស់ដីដែលបានបង្កើតក្នុង **CLUP** ផងដែរ ( ៥ ឆ្នាំទី១ )

[២] - ៥ឆ្នាំទី២ ( ២០១៣-២០១៧ ) : គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្ត ( ៥ ឆ្នាំទី២ )

[៣] - ៥ឆ្នាំទី២ ( ២០១៨-២០២២ ) : គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្តទៀត ( ៥ ឆ្នាំទី៣ )

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **១.៣. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត** | | | | | | |
| | ១.៣.១. ចំនួន ស្ពានថ្ម | ៦ | កន្លែង | ២ | ២ | ២ | |
| | ១.៣.២. ចំនួនស្ពានឈើ | | | | | | |
| | ១.៣.៣. ចំនួន ទ្វារទឹក | ១៦ | ម | ៥ | ៥ | ៦ | |
| | ១.៣.៤. ចំនួនលូឆ្លងផ្លូវ | ១៩ | កន្លែង | ៦ | ៦ | ៧ | |
| | ១.៣.៥. ផ្សេងៗ | | | | | | |
| | **២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ** | | | | | | |
| | ២.៦.១.២.១. ការសិក្សា និងអប់រំ | | | | | | |
| | ២.៦.១.២.២. សាលាមត្តេយ្យ | ១ | ខ្នង | ១ | | | |
| | ២.៦.១.២.៣. សាលាបឋមសិក្សា | ៣ | ខ្នង | ១ | ១ | ១ | |
| | ២.៦.១.២.៤. សាលាមធ្យមសិក្សា | ១ | ខ្នង | | ១ | | |
| | ២.៦.១.២.៥. សាងសង់ស្នាក់ការសហគមន៍នេសាទ | ១ | ខ្នង | | ១ | | |
| | **២.៦.១.៣. សុខភាព និងអនាម័យ** | | | | | | |
| | ២.៦.១.៤. មណ្ឌលសុខភាព | ១ | ខ្នង | | ១ | | |
| | ២.៦.១.៥. ប៉ុស្តិសុខភាព | ២ | ខ្នង | | ២ | | |
| | ២.៦.១.៦. ស្រះទឹកស្អាត | ១៥ | ស្រះ | ៥ | ៥ | ៥ | |
| | ២.៦.១.៧. អណ្តូងទឹកស្អាត | ២០ | អណ្តូង | ១០ | ៥ | ៥ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.១.៨. កន្លែងចាក់សំរាម( ១កន្លែង) | ១០០ | ម$^{២}$ | | ២ | | |
| | **២.៦.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់** | | | | | | |
| | ២.៦.១.៤.១. ប៉ុស្តិ៍នគរបាល | | | | | | |
| | ២.៦.១.៤.២. ទីតាំងផ្សារ( ១កន្លែង) | ១ | ហត | ១ | | | |
| | **២.៦.១.៥. កន្លែងគោរពបូជា** | | | | | | |
| | ២.៦.១.៥.១. ទីកន្លែងសាការៈបូជា | | | | | | |
| | ២.៦.១.៥.២. វត្តព្រះអារាម | ១ | | ១ | | | |
| | ២.៦.១.៥.៣. សាលាឆទាន | | | | | | |

## ឧបសម្ព័ន្ធ

១. ពិពណ៌នាអំពីស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ន

២. ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន

៣. បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី

៤. ក្របខ័ណ្ឌនៃការអភិវឌ្ឍ និងជំរើសនៃការប្រើប្រាស់ដីអនាគត

៥. បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ ក្នុងរយៈពេល ១៥ ឆ្នាំ

៦. ផែនទីប្រើប្រាស់ដីលំអិត

៧. ផែនទីប្រើប្រាស់ដីសាមញ្ញ

៨. ផែនទីតំបន់រសើប

៩. ផែនទីបញ្ហា មូលហេតុ និងដំណោះស្រាយ

១០. ផែនទីប្រើប្រាស់ដីអានាគត

រៀបចំដោយ:

ថ្ងៃ .........ខែ.............ឆ្នាំ.............

| បានឃើញ និង ឯកភាព: | បានឃើញ និង ឯកភាព: | បានឃើញ និង ឯកភាព: |
|---|---|---|
| កែបថ្ងៃ២៦.ខែ.ធ្នូ...ឆ្នាំ២០០៨ | ដំណាក់ចង្អេរថ្ងៃ២៣.ខែ.ធ្នូ...ឆ្នាំ២.០០៨ | អង្គោលថ្ងៃ២៣.ខែ.ធ្នូ..ឆ្នាំ២០០៨ |
| គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត | ក្រុមការងារដីរដ្ឋថ្នាក់ស្រុក | មេឃុំអង្គោល |
| ហាស់ សារ៉េត | ចេង-យុទ្ធី | ម៉ុ_ភឿន |